**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់ យឹម ទិត្យ

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 25-Oct-21, 08:00
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតឲ្យ បញ្ចប់ បោះត្រា ដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារជាបន្ទាន់**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី**

សូ មូស្សេទ្និ
Suzana TOMANOVIĆ

**<u>ផ្ញើជូន៖</u>**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

ជា លាង

Brenda J HOLLIS

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក្នុងសំណុំរឿង ០០៤**

## សេចក្ដីផ្ដើម

លោក យឹម ទិត្យ តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្ដី”) អនុលោមតាមវិធាន ២១ និង ៦៩(២)(ខ) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក (“វិធាន”) តទៅនេះសូមដាក់ *សំណើសុំដល់សហចៅក្រមស៊ើបអង្កេតឱ្យបញ្ចប់ បោះត្រា ដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារជាបន្ទាន់* (“សំណើសុំ”)។ សំណើនេះធ្វើឡើងជាការចាំបាច់ ដោយសារតាមការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ (“អ.ប.ជ”) បង្ហាញថា គ្មានមូលដ្ឋានអង្គច្បាប់អាចឱ្យសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) ចេញដីកាដំណោះស្រាយពីរនៅក្នុងសំណុំរឿង ០០៤ នោះទេ ហេតុដូច្នេះ បង្ហាញថា ដីកាដំណោះស្រាយចេញដោយសហចៅក្រមស៊ើបអង្កេតជាតិ (“ស.ច.ស.ជ”) និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“ស.ច.ស.អ”) ត្រូវចាត់ទុកជាមោឃៈ។ ដោយហេតុថា ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនៅក្នុងសំណុំរឿង ០០៤ និងយន្តការផ្លូវច្បាប់ទាំងអស់ត្រូវបានប្រើប្រាស់អស់ហើយនោះ ស្ថានភាពនីតិវិធីបច្ចុប្បន្នមានន័យថា ស.ច.ស បានទទួលសំណុំរឿង ០០៤ ហើយមានភារកិច្ចវិជ្ជមានត្រូវអនុវត្តយុត្តាធិការផ្ដាច់មុខលើរឿងក្ដីនេះ និងត្រូវបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿងនេះទៅក្នុងបណ្ណសារ។ ការខកខានមិនធ្វើដូច្នេះនឹងបង្កការខូចខាតថែមទៀត និងមិនអាចជួសជុលបានដល់សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ លោក យឹម ទិត្យ ជាពិសេស សិទ្ធិទទួលបានការសម្រេចលើកិច្ចដំណើរការនីតិវិធីរបស់ខ្លួនឱ្យបានឆាប់រហ័ស សិទ្ធិទទួលបានការប្រព្រឹត្តស្មើភាព និងសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់។ មេធាវីការពារក្ដីស្នើសុំដាក់សំណើសុំនេះជាភាសាអង់គ្លេសជាមុន ហើយសំណៅជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[1]។

## ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ អ.ប.ជ បានចេញ *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*នៅក្នុងសំណុំរឿង ០០៤[2]។

2. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) បានបញ្ជូនសំណើសុំទៅអង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) តាមសារអេឡិចត្រូនិច ស្នើសុំពន្យាររយៈពេលកំណត់ដាក់សេចក្ដីសន្និដ្ឋានជូន អ.ជ.ត.ក ពាក់ព័ន្ធនឹងករណីដែល ស.ព.អ បានអះអាងថា “ជាធម្មតា

---

[1] *សូមមើល* សារអេឡិចត្រូនិចពីអង្គភាពបកប្រែភាសា ផ្ញើជូនមេធាវីការពារក្ដី “ការបកប្រែសំណើ” ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១។

[2] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារលេខ D381/45 និង D382/43 (“សេចក្ដីពិចារណា សំណុំរឿង០០៤”)។

សេចក្តីសន្និដ្ឋាននេះវំពឹងថានឹងត្រូវដាក់ [...] ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីពិចារណាលើសំណុំរឿង ០០៤”[3]។

3. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ មេធាវីការពារក្តីបានឆ្លើយតបតាមរយៈអេឡិចត្រូនិច ដោយជំទាស់ការអះអាងរបស់ ស.ព.អ ថា សេចក្តីពិចារណារបស់ អ.ប.ជ គឺជាសេចក្តីសម្រេចបើកផ្លូវប្តឹងសាទុក្ខទៅ អ.ជ.ត.ក ហើយវាមានភាពចាំបាច់ត្រូវស្តាប់សេចក្តីសន្និដ្ឋានជាមុនពីមេធាវីការពារក្តីមុនពេលសម្រេចលើបញ្ហានេះ[4]។

4. នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ អ.ជ.ត.ក បានចេញ*សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនពាក់ព័ន្ធនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤*[5]។ អ.ជ.ត.ក បានរកឃើញថា ខ្លួនពុំអាចពិនិត្យសំណើរបស់ ស.ព.អ សុំពន្យារពេលនោះទេ ហើយសូមរំលឹកថា ស.ព.អ ត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំនេះទៅអង្គជំនុំជម្រះ[6]។ អ.ជ.ត.ក បានកត់សម្គាល់ថា មេធាវីការពារក្តី “បានលើកការជំទាស់”ដោយពុំបានអះអាងអំពីការជំទាស់ទាំងនេះ ឬ ដាក់ភ្ជាប់អេឡិចត្រូនិចរបស់មេធាវីការពារក្តី[7] ឬ យកសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីមកពិចារណានោះឡើយ[8]។

## ច្បាប់ជាធរមាន

5. វិធាន ២១ នៃវិធានផ្ទៃក្នុងចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

> ១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ញារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារ

---

[3] សារអេឡិចត្រូនិកពីសហព្រះរាជអាជ្ញាអន្តរជាតិ (“សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សារណាក្នុងសំណុំរឿង០០៤”) ចុះថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០២១។

[4] សារអេឡិចត្រូនិកពីមេធាវីការពារក្តី (“កម្មវត្ថុ៖ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សារណាក្នុងសំណុំរឿង០០៤”) ចុះថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០២១។

[5] *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សារណារបស់គាត់ពាក់ព័ន្ធនឹងសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤* ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ ឯកសារលេខ No. 2/2។

[6] *ដូចខាងលើ* កថាខណ្ឌ១១។

[7] *ដូចខាងលើ* កថាខណ្ឌ៥។

[8] *ដូចខាងលើ* ផ្នែក “សារណា” កថាខណ្ឌ៦។

ជានិច្ចដល់ផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។

ក្នុងបរិបទនេះ៖

ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឲ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។

ខ-បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត។

គ-អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី។

ឃ-ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលបានដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

[...]

៤. ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។

6. វិធាន ៦៩(២) នៃវិធានផ្ទៃក្នុងចែងថា៖

២. នៅពេលដែលគ្មានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវបិទសំណុំរឿងដោយមានបោះត្រាលើសំណុំរឿង និង៖

ក) ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីកំណត់កាលបរិច្ឆេទសវនាការ។

ខ) ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ ក្រោយផុតរយៈពេលធ្វើបណ្ដឹងឧទ្ធរណ៍។

## ឧទ្ធរណ៍

## ផ្នែកទី ១៖ យុត្តាធិការផ្ដាច់មុខរបស់ ស.ច.ស លើសំណុំរឿង ០០៤

7. ស.ច.ស បានទទួលសំណុំរឿង ០០៤ ហើយទទួលខុសត្រូវសម្រេចចុងក្រោយលើលទ្ធផលនៃសំណុំរឿងនេះ។ ដូចធ្លាប់បានប្រកាសនៅក្នុងសំណុំរឿង ០០៣ នាពេលថ្មីៗនេះ ស.ច.ស នឹងពិចារណាពីកាតព្វកិច្ចរបស់ខ្លួនក្នុងការបញ្ចប់សំណុំរឿងនេះ នៅក្រោមយុត្តាធិការដែលនៅសេសសល់ ប្រសិនបើគ្មានអង្គជំនុំជម្រះផ្សេងទៀតនៅក្នុងតុលាការនេះ "យល់ព្រមទទួលភារកិច្ច" ឈានទៅបញ្ចប់រឿងក្ដីនេះ[9]។ ការជាប់គាំងផ្នែកនីតិវិធីក្នុងសំណុំរឿង ០០៤ បញ្ជាក់យ៉ាងច្បាស់ថា ភារកិច្ចនេះមិនត្រូវហុចបន្តគ្នានោះទេ - កិច្ចរបស់ អ.ប.ជ កិច្ចរបស់ អ.ជ.ស.ដ ("អ.ជ.ស.ដ") និងកិច្ចរបស់ អ.ជ.ត.ក បានបង្ហាញថា បច្ចុប្បន្ន រឿងក្ដីនេះស្ថិតក្នុងសមត្ថកិច្ចរបស់ ស.ច.ស ដើម្បីចាត់វិធានការនៅក្នុងសំណុំរឿង ០០៤។

8. អ.ប.ជ ក្នុងសំណុំរឿង ០០៤ "**បានប្រកាស** ជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ដែលរំលោភបំពានក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក[10]។ យោងតាមសម្លេងឯកច្ឆ័ន្ទ អ.ប.ជ បានសម្រេចថា ស.ច.ស "មានភារកិច្ចតាមផ្លូវតុលាការក្នុងការសម្រេចលើបញ្ហាដែលមានវិវាទ ដែលពួកគាត់បានទទួល" ដែលមានន័យថា "ក្នុង

---

[9] សំណុំរឿង០០៣ *ដីកាបង្គាប់ឱ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង០០៣* ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២១ ឯកសារលេខ D273 ("*ដីកាបង្គាប់ឱ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់*") កថាខណ្ឌ ៥ និង៦។

[10] សេចក្ដីពិចារណា សំណុំរឿង០០៤ ទំព័រ៤៩។

ករណីដែលការខ្វែងយោបល់គ្នារបស់ពួកគាត់រារាំងពួកគាត់ មិនឱ្យឈានទៅដល់ការសម្រេចជាស្ថាពររួមគ្នាទៅលើបញ្ហាបែបនេះ ពួកគាត់នៅតែចាំបាច់ត្រូវបញ្ចប់ ភារកិច្ចតាមផ្លូវតុលាការរួមគ្នានេះ ដោយគោរពទៅតាមនីតិវិធីជាធរមាននៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក ដើម្បីធានាថា អាចឈានដល់ការសម្រេចរួមទៅលើបញ្ហាដែលស្ថិតក្នុងយុត្តាធិការរបស់ពួកគាត់”[11]។ អានុភាពផ្លូវច្បាប់នៃសេចក្តីពិចារណាជាឯកច្ឆ័ន្ទ ត្រូវបានបញ្ជាក់បំភ្លឺនៅក្នុងសំណុំរឿង ០០៣ ដែល អ.ប.ជ បានសម្រេចថា ក្រោយជូនដំណឹង “ផ្នែកនៃសេចក្តីសម្រេចនៅក្នុងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ” ស.ច.ស “ទទួលខុសត្រូវដំណើរការសំណុំរឿងនេះ”[12]។

9. នៅក្នុងស្ថានភាពមានភាពមិនស្របច្បាប់នៃនីតិវិធីដែលបណ្តាលមកពីការចេញដីកាដំណោះស្រាយពីរដោយខុសច្បាប់វាមានហានិភ័យជាក់ស្តែងភ្លាមៗចំពោះសិទ្ធិជំនុំជម្រះដោយយុត្តិធម៌របស់លោក យឹម ទិត្យ ក្នុងការទទួលបានការសម្រេចចុងក្រោយឱ្យបានឆាប់រហ័ស។ បន្ទាប់ពីទទួលបានសំណុំរឿង ០០៤ ដោយផ្អែកលើសេចក្តីពិចារណារបស់ អ.ប.ជ[13] យុត្តាធិការដែលមានជាប់មកជាមួយរបស់ ស.ច.ស ដើម្បីបញ្ចប់សំណុំរឿង ០០៤ គឺ “ត្រូវចាត់ទុកថាជាយុត្តាធិការចាំបាច់ ប្រសិនបើមានតម្រូវការចាំបាច់ដើម្បីធានាថា កិច្ចការរដ្ឋបាលតុលាការដំណើរការបានល្អ និងត្រឹមត្រូវយុត្តិធម៌”[14] ពោលគឺ ដើម្បីធានាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌ ក្នុងការសម្រេចលើសំណុំរឿងដោយឆាប់រហ័ស[15]។ សិទ្ធិនេះត្រូវបាន “រៀបចំឡើងកុំឱ្យនរណាម្នាក់ដែលត្រូវបាន

---

[11] សេចក្តីពិចារណា សំណុំរឿង០០៤ កថាខណ្ឌ១១១។

[12] សំណុំរឿង០០៣ *សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០៣* ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ឯកសារលេខ D271/5 និង D272/3 (“សេចក្តីសម្រេចរួម សំណុំរឿង០០៣”) កថាខណ្ឌ៧២។

[13] សេចក្តីសម្រេចរួម សំណុំរឿង០០៣ កថាខណ្ឌ៧២។

[14] សំណុំរឿង០០២ *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺ* ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ឯកសារលេខE284/2/1/2 កថាខណ្ឌ១២។ *សូមមើលផងដែរ* សំណុំរឿង០០២ *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារលេខ E463/1/3 កថាខណ្ឌ ១៧។

[15] វិធាន ២១ (៤)។ *សូមមើលផងដែរ* សំណុំរឿង០០៣ *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង* ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឯកសារលេខ D270/7 (“សេចក្តីសម្រេចរបស់ ស.ច.ស លើសំណើសុំឱ្យបញ្ជូនសំណុំរឿង០០៣”) កថាខណ្ឌ២៦ ដកស្រង់ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដោយដាក់បញ្ចូលច្បាប់ស្តីពីវិសោធនកម្ម ប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦)

ចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ក្នុងរយៈពេលយូរខ្លាំងពេកនោះ ស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជាអំពីជោគវាសនារបស់ខ្លួន"[16] និងរួមបញ្ចូលទាំង "សិទ្ធិទទួលបានការសម្រេចស្ថាពរលើបញ្ហាដែលបានដាក់ទៅតុលាការ"[17]។ ជាឧទាហរណ៍ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញការរំលោភលើសិទ្ធិក្នុងការទទួលបានការសម្រេចចុងក្រោយដោយឆាប់រហ័សនៅក្នុងប្រព័ន្ធច្បាប់មួយដែល "សម្លេងស្មើគ្នា [...] នាំដល់សេចក្ដីសម្រេចមួយ ដែលពុំសម្រេចជាផ្លូវការលើបញ្ហានៅក្នុងបណ្ដឹងសាទុក្ខ"[18]។

10. នៅក្នុងសំណុំរឿង 00៣ អ.ប.ជ បានរកឃើញថា ការឱ្យ ស.ច.ស ចាត់ការឡើងវិញ "នឹងធ្វើឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេតមានសមត្ថភាពបំពេញមុខងាររបស់ខ្លួន គឺមិនដូចការបន្ត

("ច្បាប់ស្ដីពីបង្កើត អ.វ.ត.ក") មាត្រា៣៣ថ្មី, ៣៥ ថ្មី (គ)។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ យោងទៅលើមាត្រា១៤(៣) (គ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ។ *សូមមើលផងដែរ រឿងក្ដី* Marini *ទល់នឹងប្រទេសអាល់បានី* តុលាការសិទ្ធមនុស្សអឺរ៉ុប បណ្ដឹងលេខ ៣៧៣៨/0២ សាលក្រម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២00៧ កថាខណ្ឌ១២0-១២៣ (សម្រេចថា ការបោះឆ្នោតដែលទទួលបានសំឡេងស្មើគ្នាក្នុងប្រព័ន្ធច្បាប់អាល់បានី ដែលបណ្ដាលឱ្យមានការប្ដឹងទៅកាន់តុលាការធម្មនុញ្ញ ដែលមិនបានសម្រេចជាផ្លូវការលើបញ្ហាទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍ "មិនបម្រើផលប្រយោជន៍នៃសច្ចភាពផ្លូវច្បាប់ឡើយ ហើយអាចដកហូតសិទ្ធប្រកបដោយប្រសិទ្ធភាពរបស់អ្នកដាក់ពាក្យបណ្ដឹង ក្នុងការទទួលបានការសម្រេចជាស្ថាពរលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន")។ *រឿងក្ដី* Frydlender *ទល់នឹងប្រទេសបារាំង* តុលាការសិទ្ធមនុស្សអឺរ៉ុប បណ្ដឹងលេខ ៣0៩៧៩/៩៦ សាលក្រម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២000 កថាខណ្ឌ៤៥ (សម្រេចថារដ្ឋទាំងឡាយដែលបានចុះកិច្ចសន្យា "ត្រូវរៀបចំប្រព័ន្ធច្បាប់របស់ខ្លួន ដើម្បីឱ្យតុលាការធានាដល់ពលរដ្ឋគ្រប់រូបនូវសិទ្ធិទទួលបានសេចក្ដីសម្រេចជាស្ថាពរក្នុងពេលវេលាសមស្រប ក្នុងការអនុវត្តសិទ្ធ និងកាតព្វកិច្ចពលរដ្ឋរបស់ខ្លួន")។ *រឿងក្ដី* Multiplex *ទល់នឹងប្រទេសក្រូអាស៊ី* តុលាការសិទ្ធមនុស្សអឺរ៉ុប បណ្ដឹងលេខ ៥៨១១២/00 សាលក្រម ចុះថ្ងៃទី១0 ខែកក្កដា ឆ្នាំ២00៣ កថាខណ្ឌ៤៥ (ពិចារណាថា "សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការ រួមបញ្ចូលទាំងសិទ្ធិចាប់ផ្ដើមកិច្ចដំណើរការនីតិវិធី និងសិទ្ធិទទួលបាន "សេចក្ដីសម្រេច" ពីតុលាការលើការខ្វែងយោបល់គ្នាផងដែរ។")

[16] សេចក្ដីសម្រេចរបស់ ស.ច.ស លើសំណើសុំឱ្យបញ្ជូនសំណុំរឿង00៣ កថាខណ្ឌ៤២ ដកស្រង់ Paul M. Taylor *សេចក្ដីអធិប្បាយស្ដីពីកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ៖ ការឃ្លាំមើលសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋដោយគណៈកម្មាធិការសិទ្ធមនុស្សអង្គការសហប្រជាជាតិ* (Cambridge University Press ឆ្នាំ២000) ទំព័រ៤0៥។

[17] *រឿងក្ដី* Marini *ទល់នឹងប្រទេសអាល់បានី* តុលាការសិទ្ធមនុស្សអឺរ៉ុប បណ្ដឹងលេខ ៣៧៣៨/0២ សាលក្រម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២00៧ កថាខណ្ឌ១២0។ *រឿងក្ដី* Multiplex *ទល់នឹងប្រទេសក្រូអាស៊ី* តុលាការសិទ្ធមនុស្សអឺរ៉ុប លេខ ៥៨១១២/00 សាលក្រម ចុះថ្ងៃទី១0 ខែកក្កដា ឆ្នាំ២000៣ កថាខណ្ឌ៤៥។

[18] *រឿងក្ដី* Marini *ទល់នឹងប្រទេសអាល់បានី* តុលាការសិទ្ធមនុស្សអឺរ៉ុប បណ្ដឹងលេខ ៣៧៣៨/0២ សាលក្រម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២00៧ កថាខណ្ឌ១២៣។

អនុវត្តលើសេចក្តីពិចារណាក្នុងសំណុំរឿង 004/2 នោះទេ"[19]។ ជាក់ស្តែង វាបង្ហាញច្បាស់ណាស់ថា កម្រិតនៃភាពបន្ទាន់ដូចគ្នាមិនឃើញមាននៅក្នុងសំណុំរឿង 004/2 ដែល ស.ច.ស.អ មិនត្រូវបានប្រគល់សិទ្ធិចាត់ការឡើងវិញរហូតដល់ 125ថ្ងៃ បន្ទាប់ពីការចេញសេចក្តីសពិចារណា របស់ អ.ប.ជ ក្នុងសំណុំរឿង 004/2[20] និងត្រឹមតែ 12ថ្ងៃ មុនពេល ស.ព.អ បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ភ្លាមៗប្តឹងការសម្រេចបញ្ចប់ជាស្ថាពរលើសំណុំរឿង 004/2 របស់អង្គជំនុំជម្រះសាលាដំបូង[21]។ ជាងនេះទៅទៀត នៅក្នុងការបញ្ចប់សំណុំរឿង 004/2 អ.ជ.ត.ក ពុំមានផលប្រយោជន៍ពីការបំភ្លឺរបស់ អ.ប.ជ នៅក្នុងសំណុំរឿង 003 នោះទេ បន្ទាប់ពីការប្រកាសជាឯកច្ឆ័ន្ទថា ដីកាដំណោះស្រាយត្រូវបានចេញដោយខុសច្បាប់នោះ សំណុំរឿងត្រូវបានបង្វិលត្រឡប់ទៅ ស.ច.ស វិញ[22]។ អ.ជ.ត.ក ធ្លាប់បានបញ្ជាក់នៅពេលសម្រេចដោយផ្អែកលើយុត្តាធិការដែលមានស្រាប់របស់ខ្លួនថា ករណីនេះអាចមានផលប៉ះពាល់នៅពេល ដែលវាជា "ចៃដន្យ" ចំពោះយុត្តាធិការចំបងរបស់អង្គជំនុំជម្រះ[23] មានន័យថា "ដែលកើតចេញពីលទ្ធផលផ្ទាល់នៃកិច្ចដំណើរការនីតិវិធី ដែលតុលាការទាំងនោះបានទទួល"[24]។ នៅក្នុងកាលៈទេសៈបច្ចុប្បន្ន ស.ច.ស បានទទួលបណ្តឹងសំណុំរឿង 004 ហើយបញ្ហានេះគឺជារឿង ដែល ស.ច.ស អាចបំពេញកិច្ច និងត្រូវបំពេញ

---

[19] សេចក្តីសម្រេចរួម សំណុំរឿង003 កថាខណ្ឌ72។

[20] *សូមមើល* សេចក្តីពិចារណា សំណុំរឿង004។ *សូមមើលផងដែរ សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតស្តីពីការបន្តតំណែងឡើងវិញចំពោះសហចៅក្រមស៊ើបអង្កេត* ចុះថ្ងៃទី24 ខែមេសា ឆ្នាំ2012។

[21] សំណុំរឿង004/2 *បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង 004/2 របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី4 ខែឧសភា ឆ្នាំ2020 ឯកសារលេខ E004/2/1។

[22] *សូមមើល* សំណុំរឿង004/2 *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង 004/2 របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី10 ខែសីហា ឆ្នាំ2020 ឯកសារលេខ E004/2/1/1/2 ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង004/2")។

[23] សូមមើល *សំណុំរឿង002 សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ* ចុះថ្ងៃទី26 ខែមិថុនា ឆ្នាំ2013 ឯកសារលេខ E286/2/1/2 កថាខណ្ឌ12។ *សូមមើលផងដែរ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី16 ខែវិច្ឆិកា ឆ្នាំ2018* ចុះថ្ងៃទី13 ខែកុម្ភៈ ឆ្នាំ2019 ឯកសារលេខ E463/1/3 កថាខណ្ឌ17 "អង្គជំនុំជម្រះរំលឹកផងដែរថា យុត្តាធិការនេះ គឺពាក់ព័ន្ធទៅនឹងកាលៈទេសៈចាំបាច់ដែលតម្រូវឲ្យមានការធានានូវកិច្ចការរដ្ឋបាលឲ្យបានល្អ និងត្រឹមត្រូវ និងប្រើប្រាស់ក្នុងករណីជាលក្ខណៈបន្ទាប់បន្សំទៅនឹងយុត្តាធិការចម្បងរបស់ខ្លួនតែប៉ុណ្ណោះ។"

[24] សំណុំរឿង002 *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ* ចុះថ្ងៃទី26 ខែមិថុនា ឆ្នាំ2013 ឯកសារលេខ E286/2/1/2 កថាខណ្ឌ12 (គូសបញ្ជាក់បន្ថែម)។

កិច្ច ដោយ ទី១ ពុំចាំបាច់តម្រូវឱ្យ អ.ជ.ត.ក អនុវត្តយុត្តាធិការរបស់ខ្លួន ឬ ធ្វើការសម្រេចអ្វីឡើង នៅក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹងបញ្ហានេះ។

11. ស.ច.ស ធ្លាប់បានអះអាងថា ខ្លួនមានអំណាចដែលមានស្រាប់អាចបង្គាប់បញ្ជាឱ្យបញ្ចប់សំណុំរឿងជាស្ថាពរតាមរយៈការផ្អាកកិច្ចដំណើរការអចិន្ត្រៃយ៍នៅពេល ដែល "ស្ថានភាព និងចក្ខុវិស័យទៅមុខទៀត [...] មិនស្របតាមគោលការណ៍គ្រឹះនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ [...]"[25]។ នៅពេលស្ថានភាពថវិការបស់ អ.វ.ត.ក មានការខ្វះខាត ហើយវាមិនច្បាស់ថាតើ អ.វ.ត.ក អាចបំពេញអាណត្តិរបស់ខ្លួនបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ឬតើនឹងមានការផ្តល់ថវិកាសម្រាប់ការពិនិត្យឡើងវិញលើដីកាដំណោះស្រាយ ការជំនុំជម្រះ និងដំណើរការប្តឹងសាទុក្ខ[26] ស.ច.ស "បានធ្វើការសិក្សាយ៉ាងច្រើនអំពីច្បាប់ទាក់ទងនឹងការផ្អាកកិច្ចដំណើរការនីតិវិធី ទាំងច្បាប់ជាតិ ទាំងច្បាប់អន្តរជាតិ" និង "ជឿជាក់ថា ទាំងច្បាប់កម្ពុជា ទាំងច្បាប់អន្តរជាតិ មានចែងអំពីសេណារីយ៉ូដែលសមស្របឱ្យចេញដីកាបែបនេះ"[27]។ ទោះបីជា ស.ច.ស ជ្រើសរើសប្រើពាក្យ "ផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ទាំងស្រុង" ជាជាងពាក្យ "លើកលែងការចោទប្រកាន់" ពួកគេយល់ឃើញថា "ការប្រើប្រាស់ពាក្យផ្សេងគ្នានេះគ្រាន់តែជាបញ្ហាពាក្យពេចន៍តែប៉ុណ្ណោះ"[28]។

12. ស.ច.ស ក៏ធ្លាប់បានទទួលស្គាល់នូវភាពចាំបាច់ក្នុងការប្រើប្រាស់អំណាចដែលមានស្រាប់នេះ "បន្ទាប់ពីដំណើរការអស់នូវយុត្តាធិការទាំងឡាយដែលមាន" នៅពេលដែលខ្លួនបានស្នើសុំអំណះអំណាងនៅក្នុងសំណុំរឿង ០០៣ ថាតើខ្លួនមានយុត្តាធិការដែលនៅសេសសល់ដើម្បី "បិទបញ្ចប់សំណុំរឿង [...] ដើម្បីផ្តល់ប្រសិទ្ធភាពដល់គោលការណ៍ទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលមានកម្រិតខ្ពស់ជាងក្នុងការសម្រេចសេចក្តីទៅលើសំណុំរឿងឱ្យបានត្រឹមត្រូវ" និង

---

[25] *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា នៅ អ.វ.ត.ក មកលើសំណុំរឿង០០៣ សំណុំរឿង០០៤ និងសំណុំរឿង០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារលេខ D355/6 កថាខណ្ឌ១៦។

[26] *សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង០០៣ សំណុំរឿង០០៤ និងសំណុំរឿង០០៤/២* ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារលេខ D355 កថាខណ្ឌ៧៥ និង៧៩។

[27] *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា នៅ អ.វ.ត.ក មកលើសំណុំរឿង០០៣ សំណុំរឿង០០៤ និងសំណុំរឿង០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារលេខ D355/6 កថាខណ្ឌ១៦។

[28] *សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង០០៣ សំណុំរឿង០០៤ និងសំណុំរឿង០០៤/២* ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារលេខ D355 កថាខណ្ឌ៨០។

"ការពារសិទ្ធិ [...] ក្នុងការទទួលបាននូវការសម្រេចជាស្ថាពរ [...] ឲ្យបានឆាប់រហ័ស"[29]។ យុត្តាធិការទាំងអស់ផ្សេងទៀតត្រូវបានអនុវត្តនៅក្នុងសំណុំរឿង ០០៤ ដោយសារគ្មានអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក ក្រៅពី ស.ច.ស ដែលមានយុត្តាធិការក្រោយពី អ.ប.ជ ចេញសេចក្តីពិចារណាដែលក្នុងនោះ អ.ប.ជ ខកខានមិនបានអនុវត្តមុខងាររបស់ខ្លួនក្នុងនាមជាសភាជាន់ខ្ពស់មួយនៅដំណាក់កាលនីតិវិធីមុនការជំនុំជម្រះ ដើម្បីផ្តល់ការសម្រេចជាក់លាក់មួយលើរឿងក្តីនេះ។

## ផ្នែកទី ២÷ សំណើសុំបញ្ចប់ បោះត្រា ដាក់បញ្ចូលសំណុំរឿង ០០៤ នៅក្នុងបណ្ណសារ

13. ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ គឺមោឃៈ ហើយគ្មានអានុភាពផ្លូវច្បាប់[30] មានន័យថាគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះណាមួយដែលមានសុពលភាពត្រឹមត្រូវនៅក្នុងសំណុំរឿង ០០៤។ មធ្យោបាយផ្លូវច្បាប់ទាំងអស់ត្រូវបានប្រើប្រាស់អស់ហើយក្នុងសំណុំរឿង ០០៤ ពីព្រោះ ស.ព.អ គ្មានវិធីតាមផ្លូវច្បាប់ផ្សេងទៀត ដែលអាចបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះបាននោះទេ។ គ្មាន ស.ច.ស អ.ប.ជ អ.ជ.ស.ដ ឬ អ.ជ.ត.ក អាចឈានទៅចេញសេចក្តីសម្រេចណាមួយដែលនឹងនាំឱ្យសំណុំរឿង ០០៤ បន្តដំណើរទៅជំនុំជម្រះនោះឡើយ។ ក្រៅពីសំណួរថាតើអង្គជំនុំជម្រះ អ.វ.ត.ក ណាមួយ នឹងបញ្ចប់សំណុំរឿង ០០៤ នោះ មិនមានបញ្ហាអង្គហេតុ ឬអង្គច្បាប់បន្ថែមទៀតដែលជាវិវាទនៅដំណាក់កាលកិច្ចនីតិវិធីនេះឡើយ។ ដើម្បីការពារសិទ្ធិជំនុំជម្រះដោយយុត្តិធម៌របស់ លោក យឹម ទិត្យ ចំពោះការសម្រេចចុងក្រោយដោយឆាប់រហ័ស សិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើភាពជាមួយជនត្រូវចោទផ្សេងទៀតនៅ អ.វ.ត.ក នៅដំណាក់កាលមុនសវនាការ និងសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ វាជាការចាំបាច់ដែល ស.ច.ស ត្រូវចាត់វិធានការភ្លាមៗបង្គាប់ឱ្យបញ្ចប់សំណុំរឿង ០០៤ និងបោះត្រារក្សាទុកសំណុំរឿងនេះនៅក្នុងបណ្ណសារ។

### i. ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនៅក្នុងសំណុំរឿង ០០៤

14. អ.ប.ជ បានពិចារណាជាឯកច្ឆន្ទថា ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ គឺជាលទ្ធផលនៃសកម្មភាពខុសច្បាប់ និងមិនត្រឹមត្រូវ[31]។ គ្មានសំណួរណាមួយសាកសួរថាតើ " អានុភាព" ឬ "ផលវិបាក" នៃការសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ គឺនាំឲ្យដីកាដំណោះស្រាយមោឃៈដែរឬទេ ដោយសារការសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ គឺជា*ការសម្រេចដោយខ្លួនឯងថា គ្មានដីកាបញ្ជូន*

---

[29] សេចក្តីសម្រេចរបស់ ស.ច.ស លើសំណើសុំឲ្យបញ្ជូនសំណុំរឿង០០៣ កថាខណ្ឌ៤២។

[30] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ កថាខណ្ឌ ៦៨។

[31] សេចក្តីពិចារណារបស់ អ.ប.ជ សំណុំរឿង០០៤ ទំព័រ៤៩។

*រឿងទៅជំនុំជម្រះដែលអាចជាមូលដ្ឋានបញ្ជូនទៅជំនុំជម្រះ*។ រាល់ការប៉ុនប៉ងរបស់ ស.ព.អ ធ្វើការបែងចែករវាងភាពមិនត្រឹមត្រូវពេញលេញតាមផ្លូវច្បាប់ចំពោះការចេញដីកាដំណោះស្រាយពីរ និងស្ថានភាពមោឃភាពនៃដីកាដំណោះស្រាយទាំងពីរ នឹងមិនទទួលបានជោគជ័យ ដោយសារតាមលក្ខណៈរបស់វា ពុំមានភាពសមហេតុផលរួចបាត់ទៅហើយ។ តាមការពិត ចៅក្រម អ.ជ.ត.ក និង ស.ច.ស ទាំងពីរ បានទទួលស្គាល់ចំណុចសំខាន់នៃច្បាប់៖ ដីកាបង្គាប់របស់តុលាការដែលគ្មានមូលដ្ឋានច្បាប់គឺមោឃៈ មានន័យថា ខ្លឹមសារ និងគោលបំណងទាំងអស់ ពុំមានអត្ថិភាពទៀតឡើយ[32]។

15. អ.ជ.ត.ក បានសម្រេចជាឯកច្ឆន្ទថា "ដោយផ្អែកលើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ដែលថា ការបំពេញកិច្ចរបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ មានន័យថា ពុំមានដីកាដំណោះស្រាយណាមួយមានសុពលភាពឡើយ" ហេតុដូច្នេះ "ក្នុងករណីដែលពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាក់លាក់ និងអាចអនុវត្តបាន" រឿងក្តីនេះត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក[33]។ អ.ជ.ត.ក បានចាត់ទុកថា ការពិភាក្សារបស់ចៅក្រម អ.ប.ជ លើអង្គសេចក្តីនៃដីកាដំណោះស្រាយនៅក្នុងមតិដាច់ដោយឡែករបស់ខ្លួនថា "មិនជាប់ពាក់ព័ន្ធ" និងជា "ការអនុវត្តដែលពុំចាំបាច់" យោងតាមអនីត្យានុកូលភាពនៃការចេញដីកាដំណោះស្រាយទាំងពីរនេះ[34]។ "កិច្ចដែលគ្មានសុពលភាពមិនអាចបង្កើតផលវិបាក ឬលទ្ធផលត្រឹមត្រូវតាមច្បាប់" ហើយ "អាស្រ័យហេតុនេះ ជាការសមហេតុផលដែលថាចំណាត់ការប្រភពដើមដែលជាដីកាដំណោះស្រាយនីមួយៗនោះ ពុំមានអានុភាពផ្លូវច្បាប់ទេ"[35]។ អ.ជ.ត.ក បានរកឃើញជាក់លាក់ថា ទឡ្ហីករណ៍ដែលលើកឡើងដោយ ស.ព.អ ថា "គោលជំហរស្វ័យប្រវត្តិ" ត្រូវយកមកអនុវត្តដើម្បីបន្តរឿងក្តីនេះ នៅពេលមិនមានសម្លេងភាគច្រើនលើសលប់ គាំទ្រដល់ដីកាលើកលែងការចោទប្រកាន់ "គេចវេស ឬមិនអើពើផលវិបាកនៃការយល់ឃើញ*ឯកច្ឆន្ទ* របស់អង្គបុរេជំនុំជម្រះដែលថា ដីកាដំណោះស្រាយគឺជាលទ្ធផលនៃ*ចំណាត់ការខុសច្បាប់ និងពុំត្រឹមត្រូវតាមច្បាប់*"[36]។

---

[32] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ កថាខណ្ឌ ៥៤ និង៦៧។

[33] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ កថាខណ្ឌ ៧១ (៥)។

[34] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ កថាខណ្ឌ ៥៣។

[35] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ កថាខណ្ឌ ៦៧។

[36] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ កថាខណ្ឌ ៦៧ (គូសបញ្ជាក់នៅក្នុងច្បាប់ដើម)។

16. ស.ច.ស បានទទួលយកសំអាងហេតុរបស់ អ.ជ.ត.ក ថា សេចក្ដីប្រកាសជាឯកច្ឆន្ទរបស់ អ.ប.ជ ថា ដីកាដំណោះស្រាយគឺជាលទ្ធផលនៃកិច្ច "ខុសច្បាប់ និងអនីត្យានុកូល" មានន័យថា ដីកាទាំងពីរ មោឃៈ។ នៅក្នុងសំណុំរឿង ០០៣ ស.ច.ស បានពិចារណាថា "មានតែផ្នែករួមគ្នានៃសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះប៉ុណ្ណោះដែលអាចមានអានុភាពចងកាតព្វកិច្ច" "ដីកាដំណោះស្រាយ *ទាំងពីរ*គួរត្រូវបានបដិសេធចោលភ្លាមៗ និងជាឯកច្ឆន្ទ ដោយសារតែវិការៈនីតិវិធីដ៏ធ្ងន់ធ្ងរ ដោយអង្គបុរេជំនុំជម្រះមិនចាំបាច់ចំណាយពេលវេលាលើការពិភាក្សាអំពីអង្គសេចក្ដីឡើយ" ហើយ "កំហុសនីតិវិធីនៃដីកាដែលមានស្ថានទម្ងន់បែបនេះ នៅក្នុងសេចក្ដីសម្រេចណាមួយ ក្នុងដំណាក់កាលស៊ើបអង្កេត ប្រាកដណាស់នឹងនាំទៅដល់ការធ្វើមោឃភាពដីកានោះ ហើយចាំបាច់ត្រូវលប់ចេញពីសំណុំរឿងដោយសារតែមោឃភាព"[37]។

17. សំអាងហេតុរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ និងសំអាងហេតុរបស់ ស.ច.ស នៅក្នុងសំណុំរឿង ០០៣ ត្រូវអនុវត្តដូចគ្នាចំពោះសំណុំរឿង ០០៤។ វិធាន ២១ ចែងអំពីការប្រព្រឹត្តដោយស្មើភាព និងសច្ចភាពផ្លូវច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក[38]។ ស.ច.ស ដដែល បាន

---

[37] សេចក្ដីសម្រេចរបស់ ស.ច.ស លើសំណើសុំឱ្យបញ្ជូនសំណុំរឿង០០៣ កថាខណ្ឌ២១។

[38] វិធាន២១ (១) (ខ) ចែងថា "បុគ្គលទាំងឡាយណាដែលរកឃើញថាស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត។" អ.ប.ជ ពិចារណាថា "ត្រូវធានាថា "ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព" គ្រប់ពេលក្នុងដំណាក់កាលមុនពេលជំនុំជម្រះ។" សេចក្ដីពិចារណា សំណុំរឿង០០៤/០២ កថាខណ្ឌ៥១ ដោយដកស្រង់វិធាន ២១។ "ចំណុចជាសារវ័ន្តមួយនៃវិធានច្បាប់ គឺគោលការណ៍សច្ចភាពគតិយុត្ត ដែលតម្រូវផងដែរថា នៅពេលតុលាការសម្រេចជាស្ថាពរលើបញ្ហាមួយ ការសម្រេចនេះមិនគួរបណ្ដាលឲ្យមានបញ្ហាចោទឡើងឡើយ"។ តុលាការសិទ្ធមនុស្សអឺរ៉ុប *រឿងក្ដី Brumărescu ទល់នឹងប្រទេសរូម៉ានី* បណ្ដឹងលេខ ២៨៣៤២/៩៥ សាលក្រម ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ កថាខណ្ឌ៦១។ តុលាការសិទ្ធមនុស្សអឺរ៉ុប *រឿងក្ដី Kehaya និងអ្នកផ្សេងទៀត ទល់នឹងប្រទេសប៊ុលហ្គារី* បណ្ដឹងលេខ ៤៧៧៩៧/៩៩ និង៦៨៦៩៨/០១ សាលក្រម ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ កថាខណ្ឌ៦១។ តុលាការសិទ្ធមនុស្សអឺរ៉ុប *រឿងក្ដី Ryabykh ទល់នឹងប្រទេសរុស្ស៊ី* បណ្ដឹងលេខ ៥២៨៥៤/៩៩ សាលក្រម ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៥១ "ក្នុងករណីមានការដាច់ចេញពីគ្នាក្នុងការអនុវត្តបទប្បញ្ញត្តិច្បាប់ដែលមានភាពប្រហែលគ្នាខ្លាំងចំពោះបុគ្គលនៅក្នុងក្រុមដែលសឹងតែដូចគ្នាបេះបិទ បញ្ហានៃសច្ចភាពគតិយុត្តិនឹងកើតមានឡើង។" តុលាការសិទ្ធមនុស្សអឺរ៉ុប *រឿងក្ដី Ştefănică និងអ្នកផ្សេងទៀត ទល់នឹងប្រទេសរូម៉ានី* បណ្ដឹងលេខ ៣៨១៥៥/០២ សាលក្រម ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ កថាខណ្ឌ៣៧ (លុបចោលការដកស្រង់ខាងក្នុង)។ ការជំនុំជម្រះសម្រេចដែលមិនស៊ីសង្វាក់គ្នាអំពីបណ្ដឹងដែលប្ដឹងដោយបុគ្គលដែលស្ថិតក្នុង

ស្ដាប់សេចក្ដីសន្និដ្ឋាននៅក្នុងសំណុំរឿង ០០៤ ស្ដីពីស្ថានភាពនីតិវិធីដូចគ្នានៃដីកាដំណោះស្រាយផ្ទុយគ្នាក្នុងសំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣។ បច្ចុប្បន្ន វាហួសដែនវិវាទដែលថា គ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះណាមួយមានសុពលភាពនៅក្នុងសំណុំរឿង ០០៤ ។

**ii. យន្តការតាមផ្លូវច្បាប់ទាំងអស់ត្រូវបានប្រើប្រាស់អស់ហើយ**

18. នៅក្នុងសំណុំរឿង ០០៤/២ យុត្តាធិការរបស់ អ.ប.ជ អ.ជ.ស.ដ និង អ.ជ.ត.ក បានអនុវត្តអស់ហើយ ចៅក្រមនៃអង្គជំនុំជម្រះទាំងនោះ ពុំបានបោះត្រាដាក់សំណុំរឿងបញ្ចូលក្នុងបណ្ណាសារឡើយ។ នៅទីបញ្ចប់ វាធ្លាក់ទៅលើ ស.ច.ស ជាអ្នកទទួលបន្ទុកការងារនេះ។ រហូតមកដល់ពេលនេះ សំណុំរឿង ០០៣ បានដើរតាមគន្លងផ្លូវដូចគ្នា។

19. ក្នុងសំណុំរឿង ០០៤/២ បន្ទាប់ពី អ.ប.ជ បានប្រកាសថា ដីកាដំណោះស្រាយទាំងពីរខុសច្បាប់ យោងតាមក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក ស.ព.អ និង សហព្រះរាជអាជ្ញាជាតិ (ស.ព.ជ) បានចេញសេចក្ដីប្រកាសព័ត៌មានមួយដោយបង្ហាញពីការបកស្រាយផ្ទុយគ្នារបស់ខ្លួនទៅលើសេចក្ដីពិចារណា។ ស.ព.អ បានទទូចថា នៅពេលអានរួមគ្នា វិធាន ១(២) និងវិធាន ៧៧(១៣)(ខ) ចែងថាក្នុងករណីដីកាបញ្ជូនរឿងទៅជំនុំជម្រះបានចេញដោយ ស.ច.ស មួយរូប ត្រូវបានបដិសេធដោយចៅក្រម អ.ប.ជ ចំនួន ៤រូប សំណុំរឿងត្រូវបញ្ជូនទៅជំនុំជម្រះ[39]។ ផ្ទុយទៅវិញ ស.ព.ជ យល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ “គឺខុសច្បាប់ ស្របតាមអំណាចសាលដីការបស់អង្គបុរេជំនុំជម្រះ” ដោយកត់សម្គាល់ថា អ.ប.ជ មិនបានបង្គាប់ឱ្យក្រឡាបញ្ជីរបស់ខ្លួនបញ្ជូនសេចក្ដីពិចារណា ឬ សំណុំរឿងទៅ អ.ជ.ស.ដ ស្របតាមការអនុវត្តពីមុនរបស់ខ្លួន[40]។

20. ភ្លាមៗក្រោយមក មេធាវីការពារក្ដី អោ អាន បានផ្ញើលិខិតមួយច្បាប់ ស្នើសុំ អ.ជ.ស.ដ បញ្ជាក់ថា ខ្លួនមិនបានទទួលបណ្ដឹងសំណុំរឿង ០០៤/២ ដោយស្របច្បាប់ឡើយ ហើយជាជម្រើស

---

ស្ថានភាពប្រហែលគ្នា នឹងនាំទៅដល់ស្ថានភាពមិនប្រាកដប្រជា ដែលធ្វើឱ្យទំនុកចិត្តរបស់សាធារណជនចំពោះតុលាការថយចុះ ហើយនឹងដកសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ពីបុគ្គល។ សូមមើល ដូចយោងខាងលើ កថាខណ្ឌ៣៨។

[39] *សេចក្ដីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង០០៤/២* ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ https://www.eccc.gov.kh/en/articles/international-and-national-ocps-press-release-case-00402 (គូសបញ្ជាក់ក្នុងច្បាប់ដើម)។

[40] *ដូចខាងលើ*។

ម្យ៉ាងទៀត ស្នើសុំពន្យារពេល និងការណែនាំ ដើម្បីដាក់អញ្ញត្រកម្ម[41]។ ជាការឆ្លើយតប ក្រឡាបញ្ជី អ.ជ.ស.ដ បានជូនដំណឹងដល់ភាគី និងចៅក្រមថា សេចក្តីពិចាណាមិនត្រូវបានជូនដំណឹងដល់ អ.ជ.ស.ដ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង មិនត្រូវបានបញ្ជូនបន្តទៅជំនុំជម្រះនោះឡើយ[42]។ ករណីនេះនាំឲ្យភាគីជាតិ និងភាគីអន្តរជាតិនៃ អ.ប.ជ ណែនាំផ្ទុយគ្នាដល់ផ្នែកគ្រប់គ្រងតុលាការ (ផ.គ.ត)៖ ចៅក្រមអន្តជាតិបានណែនាំក្រឡាបញ្ជីមួយរូប ឱ្យជូនដំណឹងជាផ្លូវការដល់ ចៅក្រម អ.ជ.ស.ដ ចំណែកចៅក្រមជាតិ ជូនដំណឹង អ.ជ.ស.ដ តាមរយៈក្រឡាបញ្ជីឱ្យបង្គាប់ ផ.គ.ត *កុំធ្វើ*ការជូនដំណឹងទៅ អ.ជ.ស.ដ ហើយស្នើសុំដាក់សំណុំរឿងទៅក្នុងបណ្ណាសារ[43]។

21. បន្ទាប់មក ចៅក្រមជាតិ និងចៅក្រមអន្តរជាតិ បានបន្តឈានទៅចេញអនុស្សរណៈផ្ទុយគ្នា ដោយបង្ហាញទស្សនៈមិនយល់ស្របលើអានុភាពផ្លូវច្បាប់នៃសេចក្តីពិចារណារបស់ខ្លួន[44]។ ប្រធាន អ.ប.ជ ចៅក្រម ប្រាក់ គឹមសាន បានទទូចថា មានតែផ្នែកនៃសេចក្តីពិចារណារបស់ អ.ប.ជ ដែលបានឯកភាពជាឯកច្ឆ័ន្ទប៉ុណ្ណោះ មានអានុភាពផ្លូវច្បាប់ ហើយការជូនដំណឹងអំពីសេចក្តី

---

[41] *សូមមើល* សំណុំរឿង00៤/២ *សំណើសុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង 00៤/0២ ទុកក្នុងបណ្ណាសារ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២0២0* ឯកសារលេខ D359/27 កថាខណ្ឌ៦ ដកស្រង់ សំណើរបស់ក្រុមមេធាវីការពារក្តី អោ អាន នៅថ្ងៃទី៣0 ខែធ្នូ ឆ្នាំ២0១៩ សុំការបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូង មិនបានទទួលសំណុំរឿង00៤/២ មកពិនិត្យតាមផ្លូវច្បាប់ទេ ហើយជាជម្រើសម្យ៉ាងទៀត ស្នើសុំពន្យាពេលវេលា និងការណែនាំសម្រាប់ដាក់អញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ ។

[42] *សូមមើល អនុស្សរណៈរបស់ អ.ប.ជ ដែលមានចំណងជើង "ការជូនដំណឹងអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង00៤/២"* ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២0២0 ឯកសារលេខ D359/35 ទំព័រ៤ ដកស្រង់សារអេឡិចត្រូនិកពី លោក លឹម ស៊ុយហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង "ព័ត៌មាន" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២0២0 វេលាម៉ោង ១ រសៀល។

[43] *អនុស្សរណៈរបស់ អ.ប.ជ ដែលមានចំណងជើង "ការជូនដំណឹងអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង 00៤/២"* ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២0២0 ឯកសារលេខ D359/35 ទំព័រ៤-៥។

[44] សំណុំរឿង00៤/២ *អនុស្សរណៈរបស់ អ.ប.ជ ដែលមានចំណងជើង "ការបញ្ជាក់បំភ្លឺទៅក្នុងសេចក្តីសម្រេចសំណុំរឿង 00៤/២"* ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២0២0 ឯកសារលេខ D359/34 ទំព័រ២។ សំណុំរឿង00៤/២ *អនុស្សរណៈរបស់ អ.ប.ជ ដែលមានចំណងជើង "ការជូនដំណឹងអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង00៤/២"* ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២0២0 ឯកសារលេខ D359/35 ទំព័រ៥។

ពិចារណាទៅ អ.ជ.ស.ដ "គឺជាការបំពានសេចក្ដីសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ"[45]។ ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានឆ្លើយតបនៅថ្ងៃដដែលនោះថា ប្រធាន អ.ប.ជ មិនមានសិទ្ធិអំណាចបង្គាប់ ផ.គ.ត ឡើយ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវប្ដឹងទៅ អ.ជ.ស.ដ អនុលោមតាមវិធាន ៧៧(១៣)(ខ) ដោយសារដីកានេះមិនត្រូវបានច្រានចោលដោយសម្លេងភាគច្រើនលើសលប់[46] ហើយថា ទោះបីជាភារកិច្ចបញ្ជូនសំណុំរឿងទៅ អ.ជ.ស.ដ ធ្លាក់ទៅលើ ស.ច.ស ក៏ដោយក៏ "តាមអានុសាសន៍ អ.ជ.ស.ដ ត្រូវបានជូនដំណឹងអំពីសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ" ដោយសារថា "ភាពនៅស្ងៀមមិនចាត់ការនៃការិយាល័យសហចៅក្រមស៊ើបអង្កេត"[47]។

22. បន្ទាប់ពីមានអនុស្សរណៈផ្ទុយគ្នារបស់ អ.ប.ជ ស.ព.អ បានស្នើសុំក្នុងពេលដំណាលគ្នា ឲ្យ អ.ជ.ស.ដ ចាត់វិធានការរដ្ឋបាលចាំបាច់ទាំងអស់ដើម្បីបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះសំណុំរឿង ០០៤/២ ហើយបានស្នើសុំ អ.ប.ជ បង្គាប់ឲ្យ ផ.គ.ត បញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងទៅ អ.ជ.ស.ដ[48]។ ផ្ទុយពី ស.ព.អ មេធាវីការពារក្ដី អោ អាន បានស្នើសុំ អ.ប.ជ "បញ្ជាក់ថា ខ្លួនបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ អនុលោមតាមវិធាន ៦៩(២)(ខ)"[49]។ ក្រឡាបញ្ជី អ.ជ.ស.ដ ក៏បានជូនដំណឹងម្ដងទៀតថា ខ្លួនពុំទទួលបានការជូនដំណឹងជាផ្លូវការអំពីសេចក្ដីពិចារណារបស់ អ.ប.ជ នោះឡើយ

---

[45] *អនុស្សរណៈរបស់ អ.ប.ជ ដែលមានចំណងជើង "ការបញ្ជាក់បំភ្លឺនៅក្នុងសេចក្ដីសម្រេចសំណុំរឿង០០៤/២"* ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកសារលេខ D359/34 ទំព័រ២។

[46] *អនុស្សរណៈរបស់ អ.ប.ជ ដែលមានចំណងជើង "ការជូនដំណឹងអំពីសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២"* ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកសារលេខ D359/35 ទំព័រ៥។

[47] *ដូចខាងលើ* ទំព័រ៤-៦។

[48] សំណុំរឿង០០៤/២ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើដល់អង្គជំនុំជម្រះសាលាដំបូងចាត់វិធានការដើម្បីទទួលបានសិទ្ធិចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងនៃសំណុំរឿង០០៤/០២ (អោ អាន)* ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារលេខ D363/1.1.8។ សំណុំរឿង០០៤/២ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យចាត់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារលេខ D359/25។

[49] សំណុំរឿង០០៤/២ *សំណើសុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង០០៤/០២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០* ឯកសារលេខ D359/27 កថាខណ្ឌ១៤។

សំណុំរឿងពុំបានបញ្ជូនមក ហើយ "វាអាស្រ័យលើអង្គបុរេជំនុំជម្រះជាអ្នកផ្តួចផ្តើមកិច្ចទាំងពីរ"[50] ចំណែកចៅក្រម អ.ប.ជ បានរក្សាជំហរដដែលលើផលវិបាកផ្លូវច្បាប់នៃសេចក្តីពិចារណានេះ[51]។

23. នៅពេល អ.ប.ជ បានដាក់សំណើសុំជាថ្មីទៅ អ.ជ.ស.ដ ឱ្យដំណើរការសំណុំរឿង ០០៤/២ អ.ជ.ស.ដ បានចេញសេចក្តីប្រកាសព័ត៌មានមួយដោយបញ្ជាក់ថា "អង្គជំនុំជម្រះសាលាដំបូងក៏មិនអាចមានសិទ្ធិចូលមើលសំណុំរឿងនោះដែរ លើកលែងតែមានការជូនដំណឹងដោយត្រឹមត្រូវ ហើយសំណុំរឿងនេះត្រូវបានបញ្ជូនមកឱ្យខ្លួន" ហើយការចេញសេចក្តីសម្រេចផ្លូវការ "មិនអាចធ្វើបាន" ដោយបានកត់សំគាល់ថា សេចក្តីប្រកាសព័ត៌មាន "ពុំមានអានុភាពផ្លូវច្បាប់"នោះទេ[52]។ ទោះបីជាចៅក្រមអន្តរជាតិ អ.ជ.ស.ដ បានពន្យល់ថា "ទទ្ធីករណ៍អាចលើកឡើងបានក្នុងកាលៈទេសៈពិសេសនៃរឿងក្តីនេះ ហើយអង្គជំនុំជម្រះសាលាដំបូងមាន*សិទ្ធិអំណាចពិសេស*ក្នុងការដោះស្រាយបញ្ហាបឋមៗដែលភាគីបានលើកឡើង" ចៅក្រមជាតិបានប្រកាសថា"នឹងពុំមានការជំនុំជម្រះក្តីលើសំណុំរឿង០០៤/២ ពាក់ព័ន្ធ អោ អាន នៅពេលនេះឬនៅពេលអនាគតឡើយ"[53]។

24. ដោយអះអាងថា អ.ជ.ស.ដ ពុំបានចាត់ការហើយសេចក្តីប្រកាសព័ត៌មានបង្កើតជា "សេចក្តីសម្រេច" បញ្ចប់សំណុំរឿង ០០៤/២ ប្រកបដោយប្រសិទ្ធភាព ស.ព.ជ ក្រោយមកបានប្តឹងសាទុក្ខទៅ អ.ជ.ត.ក[54]។ ដោយបានអះអាងថា អ.ជ.ស.ដ បានបញ្ចប់សំណុំរឿង ០០៤/២ ជាស្ថាពរ ឈរលើមូលដ្ឋានខុសច្បាប់ដោយខកខានក្នុងការផ្តល់អានុភាពលើ"គោលជំហរស្វ័យប្រវត្តិ" នៅក្នុងក្របខ័ណ្ឌ អ.វ.ត.ក ដែលអាចដំណើរការសំណុំរឿងទៅជំនុំជម្រះ ព្រមទាំងដោយខកខានមិនបានអនុវត្តយុត្តាធិការដែលមានស្រាប់របស់ខ្លួនដើម្បីសម្រេចចិត្តលើបញ្ហាដែលអាចជំនុំជម្រះនៅចំពោះមុខ និងដោយដាក់ជំហានរដ្ឋបាលបន្ថែមដើម្បីផ្តល់អានុភាពលើការជូនដំណឹងជាផ្លូវការ

---

[50] *សូមមើល* សំណុំរឿង០០៤/២ *អនុស្សរណៈរបស់ អ.ប.ជ ដែលមានចំណងជើង "ការបញ្ជូនសំណុំរឿងសំណុំរឿង០០៤/២"* ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឯកសារលេខ D359/36 កថាខណ្ឌ១៦។

[51] *ដូចខាងលើ* កថាខណ្ឌ៣៧។ សំណុំរឿង០០៤/២ *អនុស្សរណៈរបស់ អ.ប.ជ ដែលមានចំណងជើង "ការបញ្ជាក់សាជាថ្មីលើសំណុំរឿង០០៤/២"* ចុះថ្ងៃ១៦ ខែមីនា ឆ្នាំ២០២០ ឯកសារលេខ D359/37 ទំព័រ២។

[52] *សេចក្តីប្រកាសព័ត៌មានដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ស្តីពីសំណុំរឿង០០៤/២ ពាក់ព័ន្ធ អោ អាន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០* https://eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao.

[53] *ដូចខាងលើ*

[54] សំណុំរឿង០០៤/២ *បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ឯកសារលេខ E004/2/1។

អំពីសេចក្ដីពិចារណារបស់ អ.ប.ជ[55]។ មេធាវីការពារក្ដី អោ អាន បានដាក់លិខិតឆ្លើយតបថា បណ្ដឹងសាទុក្ខនេះមិនអាចទទួលយកបាន ហើយថា ការចោទប្រកាន់ អ.ជ.ស.ដ ថា ខកខាន មិនបានបញ្ជូនសំណុំរឿងទៅជំនុំជម្រះ មិនអាចមានអានុភាពបញ្ចប់សំណុំរឿង ០០៤/២ ជាស្ថាពរនោះទេ ពីព្រោះករណីនេះត្រូវបានសម្រេចដោយសេចក្ដីពិចារណា អ.ប.ជ រួចហើយ[56]។ មេធាវីការពារក្ដី លោក យឹម ទិត្យ និង មាស មុត ក៏បានស្នើសុំអនុញ្ញាតធ្វើអន្តរាគមន៍ និងដាក់សេចក្ដីសន្និដ្ឋានអំពីមូលហេតុដែល អ.ជ.ត.ក ពុំមានយុត្តាធិការជំនុំជម្រះលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ស.ព.អ[57]។

25. នៅទីបំផុត អ.ជ.ត.ក ក៏បានបញ្ចប់សំណុំរឿង ០០៤/២ ជាស្ថាពរ ដោយពិចារណាថា "ពុំមានការឯកភាពបន្ទាប់ពីរយៈពេលដប់បីឆ្នាំនៃកិច្ចស៊ើបសួរដែល អោ អាន ស្ថិតក្នុងយុត្តាធិការរបស់តុលាការ" ហើយ "ពុំមានដីកាដែលអាចអនុវត្តបាន និងជាក់លាក់" ប្រឆាំងនឹងគាត់[58]។ អ.ជ.ត.ក បានផ្ដល់ទម្ងន់ទៅលើអង្គហេតុដែលថា "ការខ្វែងយោបល់ដែលគ្មានលទ្ធភាពអាចសម្របសម្រួលបានរបស់សហចៅក្រមស៊ើបអង្កេតលើបញ្ហាថាតើ អោ អាន គប្បីត្រូវបានស៊ើបអង្កេត*ដែរឬយ៉ាងណា* បាននាំសហចៅក្រមស៊ើបអង្កេត ដល់ការចុះបញ្ជីជាផ្លូវការនូវការខ្វែងយោបល់មួយចំនួនជាមូលដ្ឋាន និងជៀសពុំរួចដល់ការចេញដីកាដំណោះស្រាយផ្ទុយគ្នា" "ភាពខ្វែងយោបល់ទាំងនេះហាក់បីដូចជាប្រកាន់នូវគំនិតរឹងត្អឹង និងខ្លាំងក្លារៀងៗខ្លួន បាននាំសំណុំរឿង ០០៤/២ បច្ចុប្បន្នទៅរកភាពទាល់ច្រក" ហើយថា កង្វះការគាំទ្ររបស់ ស.ព.ជ និងការជំទាស់នឹង ស.ព.អ "កាន់តែពង្រីកភាពទាល់ច្រកផ្នែកច្បាប់ដែលកើតមានគ្មានទីបញ្ចប់ នៅគ្រប់ជំហាននៃដំណើរការស៊ើបអង្កេតនៃសំណុំរឿង ០០៤/២ [...]"[59]។

---

[55] *ដូចខាងលើ* កថខណ្ឌ៥០-៧៦។

[56] សំណុំរឿង០០៤/២ *ចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ ឯកសារលេខ E004/2/1/1។

[57] *សំណើរបស់យឹម ទិត្យ សុំការអនុញ្ញាតលើអន្តរាគមន៍ក្នុងសំណុំរឿង០០៤/០២ ស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល* ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ ឯកសារលេខ E004/2/3។ សំណុំរឿង០០៣ *សំណើរបស់មាស មុត សុំធ្វើអន្តរាគមន៍ និងឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងការរំលត់ជាធរមាននៃសំណុំរឿង០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ឯកសារលេខ E004/2/2។

[58] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ កថាខណ្ឌ ៦៩។

[59] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ កថាខណ្ឌ ៦២ និង៦៤។

26. ក្រោយពីចេញសេចក្តីសម្រេចរបស់ អ.ជ.ត.ក ភ្លាម ស.ច.ស បានបោះត្រានិងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ដោយអនុវត្តតាមវិធាន៦៩(២)(ខ) ជាមួយនឹងការកែសម្រួលមួយចំនួន ដោយហេតុថា អ.ជ.ត.ក "មិនបានបង្គាប់ជាផ្លូវការឲ្យបោះត្រានិងដាក់បញ្ចូលក្នុងបណ្ណសារឡើយ" និងដោយហេតុថា "សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក ក្នុងន័យតឹងរ៉ឹងគឺមិនត្រូវបានចែងត្រង់ ក្រោមវិធាន៦៧(៣) នៃវិធានផ្ទៃក្នុងឡើយ"[60]។

27. ក្នុងសំណុំរឿង ០០៣ អ.ប.ជ ប្រកាសជាឯកច្ឆន្ទជាថ្មីម្តងទៀតថា ការចេញដីកាដំណោះស្រាយចំនួនពីរគឺជាការខុសច្បាប់ ដោយទទួលយកនិងដាក់បញ្ចូលនូវសំអាងហេតុជាច្រើនរបស់ខ្លួនពីសេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង០០៤/២[61]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អ.ប.ជ មិនបានអនុវត្តតាមការណែនាំរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ ដែលថា "ដោយបានប្រកាសជាឯកច្ឆន្ទថា "ការចេញដីកាដំណោះស្រាយពីរគឺជាការខុសច្បាប់ ដោយរំលោភក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក" គួរតែបានដើរមួយជំហ៊ានបន្ថែមទៅមុខនិងផ្តល់នូវការសម្រេចជាក់ស្តែងមួយ"[62]។ ផ្ទុយទៅវិញ ដូចដែលបានអនុវត្តនៅក្នុងសំណុំរឿង០០៤/២ ចៅក្រម អ.ប.ជ បានបំបែកទៅតាមក្រុមភាគីជាតិនិងភាគីអន្តរជាតិរបស់ខ្លួន និងបានចេញយោបល់ផ្ទុយគ្នាដាច់ដោយឡែករៀងៗខ្លួនទៅលើអានុភាពនៃសេចក្តីពិចារណារបស់ខ្លួន[63]។ ចៅក្រមជាតិយល់ឃើញថា សំណុំរឿង០០៣ "គួរតែតម្កល់នៅក្នុងបណ្ណសារ អ.វ.ត.ក" ដោយហេតុថាដីកាដំណោះស្រាយទាំងពីរ "មានតម្លៃដូចគ្នា និងមានសុពលភាព"[64] ខណៈដែលចៅក្រមអន្តរជាតិនៃ អ.ប.ជ បានប្រកាសថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ មានសុពលភាព និងថា ដីកាលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ គឺហួសពីអំណាចរបស់ខ្លួន[65]។

---

[60] សំណុំរឿង ០០៤/២ *ដីកាបង្គាប់ឲ្យដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ* ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ឯកសារ D363/3 កថាខណ្ឌ ៧ និង ៩។

[61] ប្រៀបធៀបទៅនឹងសំណុំរឿង ០០៣ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 និង D267/35 ("សេចក្តីពិចារណារបស់ អ.ប.ជ លើសំណុំរឿង ០០៣") កថាខណ្ឌ ៧៨-១០៩ រួម*ជាមួយនឹង*សេចក្តីពិចារណាលើសំណុំរឿង ០០៤/២ កថាខណ្ឌ ៩១-១២៤។

[62] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦១។

[63] សេចក្តីពិចារណារបស់ អ.ប.ជ លើសំណុំរឿង ០០៣ កថាខណ្ឌ ១១១-១៨, ១១៩-៣៥៨។

[64] សេចក្តីពិចារណារបស់ អ.ប.ជ លើសំណុំរឿង ០០៣ កថាខណ្ឌ ១១៨។

[65] សេចក្តីពិចារណារបស់ អ.ប.ជ លើសំណុំរឿង ០០៣ កថាខណ្ឌ ២៥៩។

28. ក្រោយពីចេញសេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង០០៣ ស.ព.អ បានស្នើ ស.ច.ស បញ្ជូនរួមគ្នាឬដាច់ដោយឡែកពីគ្នានូវសេចក្តីពិចារណានោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង សំណុំរឿង ទៅ អ.ជ.ស.ដ[66]។ ស.ព.អ លើកទឡ្ហីករណ៍ថា ចៅក្រមទាំងប្រាំរូបនៃ អ.ប.ជ បានសន្និដ្ឋាន ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ថា អ.ជ.ស.ដ "ទទួលសំណុំរឿង០០៣ ដោយស្វ័យប្រវត្តិនៅពេលចេញសេចក្តីពិចារណាទាំងនោះ"ក្រោមវិធាន៧៧(១៣)និងវិធាន៧៩(១) នៃវិធានផ្ទៃក្នុង[67] ដូច្នេះ ស.ច.ស "អាចនិងត្រូវតែអនុវត្តវិធាន៦៩(២)(ក) ដោយមានការកែ សម្រួលមួយចំនួនដើម្បីបង្គាប់ឲ្យផ្នែកគ្រប់គ្រងតុលាការបញ្ជូនសេចក្តីពិចារណា(ដែលអាចរកបាន ជាសាធារណៈ) និងតម្កល់ដីកាបញ្ជូនទៅជំនុំជម្រះនៅក្រឡាបញ្ជីនៃ អ.ជ.ស.ដ និង អនុញ្ញាតឲ្យ អ.ជ.ស.ដ ចូលទៅសំណុំរឿងដែលនៅសេសសល់តាមប្រព័ន្ធអេឡិចត្រូនិក"[68]។ ពីរថ្ងៃក្រោយ ពីដាក់សំណើរបស់ខ្លួនជាមួយ ស.ច.ស ស.ព.អ ក៏បានស្នើសុំពេលវេលាបន្ថែមក្នុងការដាក់បញ្ជី សាក្សីនិងអ្នកជំនាញក្រោមវិធាន៨០ នៃវិធានផ្ទៃក្នុងជាមួយ អ.ជ.ស.ដ[69]ដែលនៅក្នុងសំណុំរឿង ០០៤/២ អ.ជ.ស.ដ "បានបដិសេធ [...]តាមសារអេឡិចត្រូនិករបស់ក្រឡាបញ្ជីរបស់ខ្លួនចុះថ្ងៃ ទី២៧ ខែមេសា ឆ្នាំ២០២១ ដោយយោងសំអាងហេតុថាខ្លួនមិនបានទទួលការជូនដំណឹងជាផ្លូវការ អំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ"[70]

29. ស.ច.ស បានបដិសេធសំណើរបស់ ស.ព.អ សុំបញ្ជូនសំណុំរឿង ០០៣ នោះ ថាគ្មានមូលដ្ឋានគ្រប់ គ្រាន់។[71] នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ស.ច.ស បានពន្យល់អំពីមូលហេតុដែលខ្លួនមិនដាក់ការ ខ្វែងយោបល់គ្នាជូន អ.ប.ជ និងចេញដីកាដំណោះស្រាយចំនួនពីរ ការយល់អំពីភាពត្រឹមត្រូវនិង ឥទ្ធិពលនៃសេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២ ការយល់ឃើញរបស់ខ្លួនអំពី

---

[66] សំណុំរឿង ០០៣ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឲ្យបញ្ជូនសំណុំរឿង០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ឯកសារ D270។

[67] *ដូចខាងលើ* កថាខណ្ឌ ១២។

[68] *ដូចខាងលើ* កថាខណ្ឌ ១៣។

[69] *សូមមើល* សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៥។

[70] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៥។

[71] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ២៨។

ដំណោះស្រាយដែលមានសម្រាប់របស់ អ.ប.ជ ក្នុងការដោះស្រាយការទាល់ច្រកផ្នែកនីតិវិធី និងការយល់ព្រមក្នុងការបញ្ចប់រឿងក្តី[72]។

30. ទីមួយ ស.ច.ស បានពន្យល់ថា "ពុំមានចំណុចណាមួយបង្កឲ្យមាននីតិវិធីខ្វែងយោបល់ទៅលើយុត្តាធិការចំពោះមុខ អ.ប.ជ ពីព្រោះលទ្ធផលគឺត្រូវបានទាយទុកជាមុន"[73]។ ដោយកត់សម្គាល់ថា "ចៅក្រមជាតិនៃ អ.ប.ជ មានឱកាសជាច្រើនលើកក្នុងសំណុំរឿង០០៣, ០០៤/២ ព្រមទាំងសំណុំរឿង០០៤/១ និងសំណុំរឿង០០៤ បានបញ្ចេញយោបល់របស់ខ្លួនថា ខ្លួនពុំបានទទួលថា អ.វ.ត.ក មានយុត្តាធិកាលើជនត្រូវចោទនានាដែលនៅសេសសល់ក្រោយពីសំណុំរឿង០០១ និងសំណុំរឿង០០២ តាំងពីមុនបិទការស៊ើបសង្កេតជាយូរមកហើយក្នុងសំណុំរឿងណាមួយដែលនៅសេសសល់" ស.ច.ស យល់ឃើញថា "ចៅក្រមទាំងនេះគឺជាចៅក្រមដដែលនៅពេលមានដីកាដំណោះស្រាយ និងពុំមានហេតុផលត្រូវគិតថាពួកគេអាចផ្លាស់ចិត្តដោយចម្លែកក្នុងបរិបទដីកាដំណោះស្រាយ[74] ។ ដូចនេះ ស.ច.ស បានពិចារណាថាការដាក់សំណើជូន អ.ប.ជ នូវការខ្វែងយោបល់គ្នាថាតើត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះឬដីកាលើកលែងចោទប្រកាន់ "អាចមានន័យថាជាការពន្យារពេលដែលមិនចាំបាច់និងការចំណាយពេលវេលានិងធនធានឥតប្រយោជន៍" ដោយហេតុថា"យើងអាចនឹងគ្រាន់តែបានត្រឡប់មកចាប់ផ្តើមសាជាថ្មីវិញនៅប៉ុន្មានខែក្រោយ"[75]។

31. ទីពីរ ស.ច.ស បានពន្យល់អំពីរបៀបដែលពួកខ្លួន "ដូចគ្នាច្រើនទៅនឹង អ.ជ.ត.ក នៅពេលបាត់បង់អំពីរបៀបដែលចៅក្រមរបស់ អ.ប.ជ អាចនិយាយក្នុងនាមតុលាការក្នុងសំណុំរឿង០០៤/០២ ថាដីកាដំណោះស្រាយផ្សេងគ្នាគឺខុសច្បាប់ជាក់ស្តែងនិងជាការរំលោភលើក្របខ័ណ្ឌនៃ អ.វ.ត.ក គ្រាន់តែសម្រាប់ចៅក្រមជាតិ និង ចៅក្រមអន្តរជាតិបន្តទៅពិភាក្សាលើអង្គសេចក្តី និង ខ្វែងយោបល់គ្នា ក្នុងការគាំទ្រដីកាដំណោះស្រាយដែលជាលទ្ធផលគឺត្រូវប្តឹងឧទ្ធរណ៍មកខ្លួន"[76]។ ពួកគេសន្និដ្ឋានថា "ជំហរគួរឲ្យភ្ញាក់ផ្អើលរបស់ចៅក្រមអន្តរជាតិក្នុងសេចក្តីពិចារណាក្នុងសំណុំរឿង

[72] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ១៥-២៥។

[73] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ១៥។

[74] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ១៥។

[75] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ១៥។

[76] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ២១។

០០៣ ដែលថាកំហុសនេះមិនធ្វើឲ្យដីកាដំណោះស្រាយមោឃៈនោះ គឺពិបាកយល់ ដោយពិចារណាទៅលើដីកាបញ្ចប់សំណុំរឿង០០៤/២ របស់ អ.ជ.ត.ក[77]។

32. ទីបី ស.ច.ស យល់ឃើញថា អ.ប.ជ "មានឱកាសពីរលើកក្នុងការបំបែកភាពទាល់ច្រកដោយខ្លួនឯង តាមបីរបៀប" ដោយបញ្ជាក់ឡើងវិញនូវដំណោះស្រាយដែលលើកឡើងដោយមេធាវីការពារក្តី ក្នុងបណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ លើដីកាដំណោះស្រាយទាំងពីរ៖

- ជាឯកច្ឆន្ទបង្វិលត្រឡប់សំណុំរឿងមកពួកយើងវិញ ដោយសារតែកំហុសនីតិវិធីធ្ងន់ធ្ងរ ហើយមិនចាំបាច់ពាក់ព័ន្ធជាមួយនឹងអង្គសេចក្តីឡើយ ដោយមានសេចក្តីណែនាំឲ្យចេញដីកាដំណោះស្រាយតែមួយរួមគ្នា

- ឬ បំពេញកិច្ចដោយខ្លួនឯងផ្ទាល់ជាឯកច្ឆន្ទ ដោយអនុវត្តវិធានរកសំឡេងមិនបាន ហើយបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

- ឬ ដោយសារតែមានការខ្វែងយោបល់គ្នាដែលមាននៅជាក់ស្តែងនៅក្នុង អ.ប.ជ ដែលបង្ហាញតាមរយៈសេចក្តីពិចារណាទាំងពីរនោះ ធ្វើការបិទបញ្ចប់សំណុំរឿង ដូចដែល អ.ជ.ត.ក បានសម្រេចជាស្ថាពរក្នុងសំណុំរឿង០០៤/២[78]។

33. ស.ច.ស បង្ហាញនូវក្តីសោកស្តាយថា "អង្គបុរេជំនុំជម្រះត្រូវប្រឈមជាមួយការសម្រេចផ្ទុយរបស់អង្គជំនុំជម្រះតុលាការកំពូល ដោយការជ្រើសរើសមិនអនុវត្តតាមចំណុចណាមួយខាងលើ [...] បង្កើតឲ្យមាននូវស្ថានភាពបច្ចុប្បន្នដោយមិនមានគោលដៅច្បាស់លាស់ និងបង្កើតឡើងនូវក្តីមន្ទិលធ្ងន់ធ្ងរ អំពីអត្ថន័យជាក់ស្តែងនៃវិធានរកសំឡេងមិនបាន ដូច្នេះជាលទ្ធផលគឺបោះបង់ចោលការទទួលខុសត្រូវ សម្រាប់ដំណោះស្រាយត្រឹមត្រូវចំពោះសំណុំរឿង ដែលមានផលវិបាកធ្ងន់ធ្ងរចំពោះសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ក្រុមការពារក្តី [...]"[79]។

---

[77] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ២១។

[78] *បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/18 និង D382/21 កថាខណ្ឌ ៣៧-៤០។ សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ២៥។

[79] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ២៥។

34. ចំណុចចុងក្រោយ ស.ច.ស បានប្រកាសថាប្រសិនបើ "គ្មានស្ថាប័នតុលាការដទៃណានៅក្នុងតុលាការនេះមានបំណងចង់ទទួលយកមកអនុវត្តដោយខ្លួនឯងនូវមធ្យោបាយណាមួយនោះ" ជាជម្រើសចុងក្រោយបំផុត (*ultima ratio*) និងបន្ទាប់ពីដំណើរការអស់នូវយុត្តាធិការទាំងឡាយដែលមានពួកគាត់នឹងបើកឱកាសទទួលយកឬស្នើសុំនូវទឡ្ហីករណ៍នានាអំពីបញ្ហាថាតើពួកគាត់មានយុត្តាធិការនៅសេសសល់ពិសេសណាមួយដែលជាមធ្យោបាយចុងក្រោយបំផុត ក្នុងការបិទបញ្ចប់សំណុំរឿងដោយខ្លួនឯង [...]ដើម្បីផ្តល់ប្រសិទ្ធភាពដល់គោលការណ៍ទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលមានកម្រិតខ្ពស់ជាង ក្នុងការសម្រេចសេចក្តីទៅលើសំណុំរឿងឲ្យបានត្រឹមត្រូវ និងដើម្បីការពារសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការសម្រេចជាស្ថាពរទៅលើសំណុំរឿងប្រឆាំងនឹងខ្លួនឲ្យបានឆាប់រហ័ស"[80]។ ពួកគាត់បានពិចារណាឃើញថា "កិច្ចនីតិវិធីប្រឆាំងនឹង មាស មុត អាចនៅរង់ចាំការសម្រេចជារៀងរហូត ប្រសិនបើស្ថានភាពបន្ទាប់ពីសេចក្តីពិចារណាលើសំណុំរឿង០០៣ ដូចបានរៀបរាប់ខាងលើ គឺជាដំណាក់កាលចុងក្រោយនោះ"[81]។ ដោយកត់សម្គាល់ថា ស.ច.ស.ជ "ពុំចាត់ទុកថាខ្លួនត្រូវជាប់កាតព្វកិច្ចដោយវិធានរកសំឡេងមិនបាន" ស.ច.ស.អ យល់ឃើញឃើញថា "ប្រភេទនៃដីកាដំណោះស្រាយរួមតែមួយដែលអាចមានសម្រាប់ ស.ច.ស ទាំងពីររូបគឺ "ការបិទបញ្ចប់សំណុំរឿង ដោយផ្អែកលើមូលដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌ [...]ឬជាជម្រើសមួយទៀត គឺដោយសារតែមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព ដូចដែលបានសម្រេចដោយ អ.ជ.ត.ក ក្នុងសំណុំរឿង០០៤/២"[82]។

35. នៅក្នុងបរិបទនេះ ស.ច.ស បានប្រកាសថា "ពុំមានចៅក្រមស៊ើបអង្កេតណាម្នាក់នឹងបញ្ជូន សំណុំរឿងតែម្នាក់ឯងឡើយ"[83]។ ស.ច.ស បានពិចារណាថា "ដំណោះស្រាយ"នេះដែលស្នើឡើងដោយចៅក្រមអន្តរជាតិនៃ អ.ប.ជ និង ស.ព.អ "ជាខ្លឹមសារគឺពុំខុសគ្នាពីមានដីកាដំណោះស្រាយផ្សេងគ្នាចំនួនពីរសាជាថ្មី" ដោយហេតុថា ក៏ដូចជា ស.ច.ស.អ បញ្ជូនរឿងទៅ អ.ជ.ស.ដ ស.ច.ស.ជ អាចបង្គាប់ឲ្យបោះត្រានិងដាក់ក្នុងបណ្ណសារ ពោលគឺ ការមិនសម្រេចរបស់ អ.ប.ជ គឺជាឯកសារសំអាងផ្លូវច្បាប់សម្រាប់ដីកាដំណោះស្រាយទាំងពីរឬដីកាដំណោះស្រាយណាមួយ"[84]។ ប៉ុន្តែ

---

[80] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៤២។

[81] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ២៥។

[82] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៣៦។

[83] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៣៧។

[84] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៣៧។

ទោះជាយ៉ាងណាក្តី ស.ច.ស ពិចារណាឃើញថាខ្លួនខ្វះយុត្តាធិការក្នុងការសម្រេចជោគវាសនាសំណុំរឿង០០៣ ដោយហេតុថាវាស្ថិតនៅលើ អ.ប.ជ ក្នុងការកំណត់ការទទួលយកដីមបណ្តឹងរដ្ឋប្បវេណី ហើយ ការបដិសេធរបស់ អ.ជ.ស.ដ លើសំណើសុំបន្ថែមពេលវេលារបស់ ស.ព.អ អាចបើកផ្លូវចុងក្រោយសម្រាប់ការសម្រេចមួយរបស់ អ.ជ.ត.ក ដូចក្នុងសំណុំរឿង០០៤/២"[85]។ ហេតុដូច្នេះ ពួកគេបានជំរុញយ៉ាងច្បាស់លាស់ឲ្យ ស.ព.អ ប្តឹងឧទ្ធរណ៍នៅ អ.ប.ជ ដើម្បីអនុញ្ញាតឲ្យខ្លួនពិចារណាឡើងវិញឬយ៉ាងហោចណាស់បំភ្លឺទស្សនៈរបស់ខ្លួនទៅលើខ្លឹមសារការទទួលយកជាឯកច្ឆន្ទដោយចៅក្រម អ.ប.ជ និងអានុភាពចងកាតព្វកិច្ចតាមវិធានរកសំឡេងមិនបាន ភាពធ្ងន់ធ្ងរនៃការរំលោភបំពានលើវា អានុភាពនៃការមិនអនុវត្តតាម លើបញ្ហានៃការជំនុំជម្រះក្តីដោយយុត្តិធម៌នៃសំណុំរឿងនេះ និងនាំទៅដល់ការបញ្ចប់សំណុំរឿងនេះឲ្យបានត្រឹមត្រូវតាមសិទ្ធិអំណាចដែលអង្គបុរេជំនុំជម្រះបានប្រកាសថាខ្លួនមាននោះ"[86]។

36. ស.ព.អ ជ្រើសរើសមិនប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់ ស.ច.ស ប៉ុន្តែបែរជាដាក់សារណាជូនទៅ អ.ប.ជ ដោយស្នើ អ.ប.ជ បញ្ចប់ដំណាក់កាលបុរេជំនុំជម្រះនៃកិច្ចនីតិវិធីសំណុំរឿង០០៣[87]។ ស.ព.អ បានស្នើថាការណ៍នេះនឹងស្របជាមួយ ការសន្និដ្ឋានជាឯកច្ឆន្ទរបស់អ.ប.ជ ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៣ និង គោលជំហរស្វ័យប្រវត្តិនៅក្នុងក្របខណ្ឌគតិយុត្ត អ.វ.ត.ក ដែលគាត់បានអះអាងអាណត្តិថា សំណុំរឿងបន្តទៅជំនុំជម្រះ[88]។ ទន្ទឹមពេលគ្នានេះដែរ មេធាវីការពារក្តី មាស មុត បានស្នើ អ.ប.ជ បិទបញ្ចប់ បោះត្រា និង ដាក់សំណុំរឿង០០៣ទៅក្នុងបណ្ណសារ ដើម្បីធានានូវសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានកិច្ចនីតិវិធីប្រឆាំងនឹងខ្លួនត្រូវបានបញ្ចប់ក្នុងពេលសមស្រប[89]។

37. អ.ប.ជ បានបដិសេធសំណើទាំងពីរ ដោយសន្និដ្ឋានថាខ្លួនបានសម្រេចលើចំណុចដែលបានលើកនៅក្នុងសំណើនៅត្រង់ផ្នែកសម្រេចសេចក្តីនៃសេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង០០៣ រួច

---

[85] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៤០។

[86] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៤៣។

[87] សំណុំរឿង ០០៣ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣* ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D271/1។

[88] *ដូចខាងលើ* ឯកសារ D271/1។

[89] សំណុំរឿង ០០៣ *សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ* ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D272 កថាខណ្ឌ ៤៧-៧៣។

ហើយ[90]។ ជាឯកច្ឆន្ទ អ.ប.ជ សន្និដ្ឋានថាពុំមានកាតព្វកិច្ចសម្រាប់ខ្លួនក្នុងការសម្រេចជាឯកច្ឆន្ទថា ស.ច.ស ទទួលខុសត្រូវដំណើរការរឿងក្តីអនុលោមតាមវិធាន៧៧(១៣)និង(១៤)នៃវិធានផ្ទៃក្នុង និងថាការធ្វើឱ្យដូចដើមឡើងវិញរបស់ ស.ច.ស ធ្វើឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងជំហរមួយក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន មិនដូចក្រោយពេលសេចក្តីពិចារណាក្នុងសំណុំរឿង០០៤/២ ត្រូវបានចេញឡើយ[91]។ អ.ប.ជ ក៏រម្លឹកផងដែរថាខ្លួនអាចបដិសេធសំណើដែលមិនចាំបាច់ និង បង្កើតសក្តានុពលក្នុងការតទល់ក្តីមិនចប់មិនហើយ ដូចជានៅពេលដែលសំណើតវ៉ាបញ្ហាមួយ ដែលមានលក្ខណៈដូចគ្នា (ទាំងអង្គហេតុ ទាំងអង្គច្បាប់)ទៅនឹងបញ្ហាដែលបានពិចារណាហើយដោយអង្គជំនុំជម្រះពាក់ព័ន្ធនឹងភាគីដដែល ដែលលើបញ្ហានោះខ្លួនពុំអាចរកសំឡេងមតិភាគច្រើនលើសលុបចំនួន៤សំឡេងក្នុងការចេញសេចក្តីសម្រេចមួយ ដែលចៅក្រមអាចរំពឹងថារក្សាជំហរស្រដៀងគ្នា[92]។ ជាពិសេស អ.ប.ជ បានបដិសេធថាមិនបានជាប់ទាក់ទងនឹងការប្រព្រឹត្តិរបស់សហចៅក្រមស៊ើបអង្កេតកន្លងទៅ ឬសំណើដែលបានទទួលយករួចមកហើយ ក៏ដូចជាការអនុវត្តមិនត្រឹមត្រូវដែលនាំទៅរកភាពបរាជ័យដែលអ្នកបង្កទំនងជាមិនអាចជម្នះបាន[93]។

38. ចាប់ពីពេលនោះមក ដោយមានមូលហេតុសមស្របផ្ទាល់ខ្លួន ស.ច.ស បានជូនដំណឹងដល់ភាគីថាពេលវេលាបានមកដល់ហើយ ដោយរម្លឹកភាគីអំពីចេតនារបស់ខ្លួនក្នុងការស្នើដាក់សារណាអំពីយុត្តាធិការដែលសេសសល់ក្នុងការបិទបញ្ចប់សំណុំរឿង[94]។ ស.ច.ស បានពិចារណាថា បញ្ហាតែមួយដែលត្រូវសម្រេចគឺថាតើ[ស.ច.ស] មានយុត្តាធិការសេសសល់ក្នុងការបិទបញ្ចប់សំណុំរឿងដែរឬទេ ដោយហេតុថាសំណុំរឿងនេះបានមកដល់ចំពោះមុខ អ.ប.ជ ពីរលើកហើយ និងបញ្ហាច្បាប់ពាក់ព័ន្ធត្រូវបានពិភាក្សាដេញដោលដោយភាគីយ៉ាងពេញទំហឹង។ ពុំមានទិដ្ឋភាពថ្មីទំនងជាកើតឡើងឡើយ[95]។ ដោយកត់សម្គាល់លទ្ធភាពថា ស.ព.អ អាចមានបំណងដាក់ជូន អ.ជ.ត.ក នូវសំណើសុំបិទបញ្ចប់ក្នុងសំណុំរឿង០០៤/២ ស.ច.ស បានបង្គាប់ឱ្យ ស.ព.អ ប្រកាសថាតើ ស.ព.អ មានបំណងចង់ដាក់សំណើទៅ អ.ជ.ត.ក លើរឿងក្តីនេះឬទេ ហើយប្រសិនបើមិនមាន

[90] សេចក្តីសម្រេចរួមក្នុងសំណុំរឿង ០០៣។

[91] សេចក្តីសម្រេចរួមក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៦៨, ៧២, ៧៧។

[92] សេចក្តីសម្រេចរួមក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៧៧។

[93] សេចក្តីសម្រេចរួមក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៧៦។

[94] ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង កថាខណ្ឌ ៦។

[95] ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង កថាខណ្ឌ ៦។

បំណងដាក់ទេ បង្គាប់ឲ្យភាគីដាក់មតិយោបល់ណាមួយដែលពួកគេអាចមានអំពីបញ្ហាតែមួយគត់ គឺយុត្តាធិការ [...][96]។ បន្ទាប់មក ស.ព.អ ជូនដំណឹងថាខ្លួនប្ដឹងឧទ្ធរណ៍ទៅអ.ជ.ត.ក[97] ។

39. ឥឡូវ ជាការច្បាស់ណាស់ គឺពុំមានបញ្ហាគតិយុត្តិថ្មីឡើយក្នុងសំណុំរឿង០០៤។ បញ្ហាពាក់ព័ន្ធទាំងអស់ ត្រូវបានពិភាក្សាដោយភាគីនិងបានឆ្លងកាត់ ស.ច.ស អ.ប.ជ និង អ.ជ.ត.ក៖

ក. *ថាតើក្របខ័ណ្ឌ អ.វ.ត.ក អនុញ្ញាតឲ្យចេញដីកាដំណោះស្រាយចំនួនពីរឬទេ៖* ការចេញដីកាដំណោះស្រាយចំនួនពីរគឺខុសច្បាប់ រំលោភក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក[98] ។

ខ. *ថាតើដីកាដំណោះស្រាយណាមួយឬដីកាដំណោះស្រាយទាំងពីរក្នុងសំណុំរឿង០០៤ ត្រូវចាត់ទុកជាបានការនៅពេលត្រូវបានប្រកាសថាខុសច្បាប់៖ គ្មានដីកាដំណោះស្រាយណាមួយត្រូវចាត់ទុកជាបានការឡើយដោយហេតុថាដីកាដំណោះស្រាយទាំងពីរត្រូវចាត់ទុកជាមោឃៈ និងគ្មានអានុភាពគតិយុត្តឡើយ[99] ។*

គ. *ថាតើយោបល់ដោយឡែករបស់ចៅក្រមជាតិនិងចៅក្រមអន្តរជាតិនៃ អ.ប.ជ ក្នុងសំណុំរឿង ០០៤ មានអានុភាពគតិយុត្តដែរឬទេ។* យោបល់ដោយឡែកគឺពុំពាក់ព័ន្ធ និង មានតែសេចក្ដីពិចារណាជាឯកច្ឆន្ទរបស់ អ.ប.ជ មានអានុភាពគតិយុត្តិ[100]។

ឃ. *ថាតើអ.ជ.ស.ដ ទទួលសំណុំរឿងដោយស្វ័យប្រវត្តិនៅពេលចេញសេចក្ដីពិចារណាលើសំណុំរឿង០០៤ អនុលោមតាមវិធាន៧៧(១៣) និង ៧៩(១) នៃវិធានផ្ទៃក្នុង។* ដោយពិចារណាលើការប្រកាសជាឯកច្ឆន្ទរបស់ អ.ប.ជ ថាសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេតក្នុងការ

---

[96] ដីកាបង្គាប់ឲ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង កថាខណ្ឌ ៧ ទំព័រ ២-៣។

[97] សំណុំរឿង ០០៣ *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេត សុំឲ្យប្រកាសថាតើសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងប្ដឹងទៅអង្គជំនុំជម្រះតុលាការកំពូលដែរឬទេ* ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D273/1 កថាខណ្ឌ ២។

[98] សេចក្ដីពិចារណាលើសំណុំរឿង ០០៤ ទំព័រ ៦៩-៧០។

[99] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៧។ សេចក្ដីសម្រេចរបស់ ស.ច.ស ស្ដីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ២១។

[100] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៥៣។ សេចក្ដីសម្រេចរបស់ ស.ច.ស ស្ដីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ២៣។

ចេញដីកាចំនួនពីរផ្សេងគ្នានិងផ្ទុយគ្នាគឺចាត់ទុកជាមោឃៈ អ.ប.ជ មិនអាចទទួលបណ្តឹង និងពុំអាចអនុញ្ញាតនិង/ឬជូនដំណឹងអំពីការដាក់ឯកសារអេឡិកត្រូនិកឡើយ[101]។

ង. *ថាតើ គោលជំហរស្វ័យប្រវត្តិណាមួយអាចអនុវត្តបាននៅក្នុងសំណុំរឿង០០៤ ដើម្បីដំណើរការរឿងក្តីទៅជំនុំជម្រះនៅពេលដែលដីកាដំណោះស្រាយត្រូវបានប្រកាសថាខុសច្បាប់។* បើទោះជាវត្ថុបំណងនៃយន្តការដោះស្រាយការខ្វែងគំនិតគ្នាគឺដើម្បីបង្ការភាពទាល់ច្រកកុំឲ្យភ្ជាត់ចេញពីកិច្ចនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏សំណុំរឿងមួយមិនអាចបន្តទៅជំនុំជម្រះដោយគ្មានដីកាដំណោះស្រាយដែលមានសុពលភាពមួយឡើយ[102]។

ច. *តើការិយាល័យរបស់ អ.វ.ត.ក មួយណាដែលទទួលខុសត្រូវដំណើរការរឿងក្តី ក្រោយពីមានសេចក្តីពិចារណារបស់ អ.ប.ជ។* អ.ប.ជ ដែលជាអង្គជំនុំជម្រះឧទ្ធរណ៍ខ្ពស់ជាងគេនៅក្នុងដំណាក់កាលមុនជំនុំជម្រះនៃកិច្ចនីតិវិធីបានបំភ្លឺថា ស.ច.ស ទទួលខុសត្រូវលើការដំណើរការរឿងក្តីក្រោយពីមានសេចក្តីពិចារណារបស់ អ.ប.ជ[103]។

ឆ. *ថាតើ ស.ច.ស មួយរូបអាចបញ្ជូនសំណុំរឿងដែរឬទេ។* ស.ច.ស បានប្រកាសរួមគ្នាថាពុំមាន ស.ច.អ រូបណានឹងបញ្ជូនសំណុំរឿងម្នាក់ឯងឡើយ[104]។

ជ. *តើនណាទទួលសំណុំរឿងក្រោយពេល អ.ប.ជ សន្និដ្ឋានជាឯកច្ឆន្ទនៅក្នុងសេចក្តីពិចារណារបស់ខ្លួនថាដីកាដំណោះស្រាយទាំងពីរខុសច្បាប់?* ជាឯកច្ឆន្ទ អ.ប.ជ សន្និដ្ឋានថា ពុំមានកាតព្វកិច្ចសម្រាប់ខ្លួនក្នុងការសម្រេចជាឯកច្ឆន្ទថា ស.ច.ស ទទួលខុសត្រូវដំណើរការរឿងក្តីអនុលោមតាមវិធាន៧៧(១៣)និង(១៤)នៃវិធានផ្ទៃក្នុង និងថាការធ្វើឲ្យដូចដើមឡើងវិញរបស់ ស.ច.ស ធ្វើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងជំហរមួយក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនមិនដូចក្រោយពេលសេចក្តីពិចារណាក្នុងសំណុំរឿង០០៤/២ត្រូវបានចេញឡើយ[105]។

---

[101] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៥៣-៥៤។

[102] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៨។ សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៣៦។

[103] សេចក្តីសម្រេចរួមក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៧២។

[104] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៣៧។

[105] សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង ០០៣ កថាខណ្ឌ ៣៧។

### iii. ស.ច.ស ត្រូវតែបិទបញ្ចប់សំណុំរឿង004 ដើម្បីធានាសិទ្ធិរបស់ យឹម ទិត្យ ក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយយុត្តិធម៌

40. អាជ្ញាបញ្ជាសម្រាប់ ស.ច.ស ក្នុងការបំពេញកិច្ចត្រូវបានទទួលស្គាល់ដោយសំណើរបស់ខ្លួនសុំដាក់សារណាអំពីយុត្តាធិការសេសសល់ក្នុងសំណុំរឿង003 ដែលបានជូនដំណឹងដល់ភាគី [...]ដែលថាប្រសិនបើគ្មានអង្គជំនុំជម្រះផ្សេងទៀតនៅក្នុងតុលាការនេះ យល់ព្រមទទួលភារកិច្ច ឈានទៅបញ្ចប់រឿងក្ដីនេះទេ [ពួកគាត់] អាចពិចារណា ឬស្នើឲ្យដាក់សារណាស្ដីពីយុត្តាធិការសេសសល់របស់ខ្លួនក្នុងការបិទបញ្ចប់សំណុំរឿង[106]។ ដោយសារហានិភ័យចំពោះមុខនៃការរំលោភសិទ្ធិរបស់ យឹម ទិត្យ ជាពិសេសសិទ្ធិរបស់ យឹម ទិត្យ ក្នុងការទទួលបានការសម្រេចឆាប់រហ័សលើរឿងក្ដីប្រឆាំងនឹងគាត់ សិទ្ធិទទួលបានការប្រព្រឹត្តស្មើគ្នា និង សច្ចភាពផ្លូវច្បាប់ ស.ច.ស ត្រូវអនុវត្តយុត្តាធិការសេសសល់របស់ខ្លួននៅក្នុងសំណុំរឿង004 ជាបន្ទាន់។

41. ការខ្វែងយោបល់គ្នាដែលបានញាំញីភាគីជាតិនិងភាគីអន្តរជាតិនៃ អ.វ.ត.ក លើចំណុចថាតើ យឹម ទិត្យ ស្ថិតនៅក្នុងយុត្តាធិការតុលាការឬទេនោះ បានបណ្ដាលឲ្យកិច្ចនីតិវិធីនៅកណ្ដាលទីដោយមិនទៀងទាត់ ដែលជាការរំលោភសិទ្ធិគាត់ក្នុងការទទួលបានការសម្រេចចុងក្រោយឆាប់រហ័សប្រឆាំងនឹងគាត់[107]។ រយៈពេល១៥ឆ្នាំ បានកន្លងផុតទៅចាប់តាំងពីកិច្ចស៊ើបអង្កេតបឋមត្រូវបានបើកលើ យឹម ទិត្យ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦[108] ដោយគ្មានការបិទបញ្ចប់កិច្ចនីតិវិធីមុនការជំនុំជម្រះក្រោយពីការសម្រេចរបស់ អ.ប.ជ លើ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១[109]។ ការខកខានក្នុងការបិទបញ្ចប់សំណុំរឿង004នៅចំពោះមុខការពន្យារពេលដ៏អាក្រក់និងគ្មានយុត្តិកម្មរំលោភសិទ្ធិជាសារវន្តរបស់ យឹម ទិត្យក្នុងការទទួលបានការសម្រេចចុងក្រោយឆាប់រហ័សទៅលើរឿងក្ដីរបស់គាត់ ដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់កម្ពុជា ច្បាប់

---

[106] សេចក្ដីសម្រេចរបស់ ស.ច.ស ស្ដីពីការបញ្ជូនរឿងសំណុំរឿង 003 កថាខណ្ឌ ៤២។

[107] សេចក្ដីសម្រេចរបស់ ស.ច.ស ស្ដីពីការបញ្ជូនរឿងសំណុំរឿង 003 កថាខណ្ឌ ២៦ និង ៤២។ ក្រុមមេធាវីការពារក្ដីក៏បានដាក់បញ្ចូលទស្សីករណ៍ជាសំអាង ដែលបានលើកឡើងនៅក្នុង *បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D382/22 កថាខណ្ឌ ៣៧-៥៣។

[108] *ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម* ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D304/2 កថាខណ្ឌ ៧។

[109] សេចក្ដីពិចារណាលើសំណុំរឿង 004។

បង្កើត អ.វ.ត.ក និង ច្បាប់អន្តរជាតិ[110]។ ភាពស្ទាក់ស្ទើរណាមួយរបស់ ស.ច.ស ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងការបិទបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណាសារជាបន្ទាន់នឹងបណ្តាលឲ្យពន្យារពេលមិនចាំបាច់និងមិនអាចកែតម្រូវបានចំពោះកិច្ចនីតិវិធីសំណុំរឿង00៤ ជាការរំលោភវិធាន២១នៃវិធានផ្ទៃក្នុង។ ការជាប់គាំងផ្នែកនីតិវិធីក្នុងសំណុំរឿង 00៤ បញ្ជាក់យ៉ាងច្បាស់ថា ភារកិច្ចនេះមិនត្រូវហុចបន្តគ្នានោះទេ - កិច្ចរបស់ អ.ប.ជ កិច្ចរបស់ អ.ជ.ស.ដ និងកិច្ចរបស់ អ.ជ.ត.ក បានបង្ហាញថា បច្ចុប្បន្ន រឿងក្តីនេះស្ថិតក្នុងសមត្ថកិច្ចរបស់ ស.ច.ស ដើម្បីចាត់វិធានការនៅក្នុងសំណុំរឿង 00៤ ។

42. ចំពោះការប្រព្រឹត្តស្មើគ្នាវិញ មេធាវីការពារក្តីកត់សម្គាល់ថា នៅក្នុងការបិទបញ្ចប់សំណុំរឿង 00៤/0២ អ.ជ.ត.ក បានពិចារណាឃើញថាពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព និង ក្រោយពីការស៊ើបអង្កេតអស់រយៈពេល១៣ឆ្នាំពុំមានការព្រមព្រៀងថា អោ អាន ស្ថិតនៅក្នុងយុត្តាធិការតុលាការឡើយ[111] ។ សំអាងហេតុនេះត្រូវតែអនុវត្តចំពោះ យឹម ទិត្យ ដើម្បីចៀសវាងការរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានការព្រឹត្តស្មើគ្នានិងសច្ចភាពផ្លូវច្បាប់[112]។តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ទិដ្ឋភាពមួយនៃនីតិរដ្ឋគឺគោលការណ៍សច្ចភាពផ្លូវច្បាប់ដែលតម្រូវក្នុងចំណោម

---

[110] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២00៣ មាត្រា ១២(២) និង ១៣(១)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ *ថ្មី* និង ៣៥ *ថ្មី*។ វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(គ)។ *សូមមើលផងដែរ:* កតិកាសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលត្រូវបានធ្វើវិសោធនកម្មដោយពិធីសារលេខ ១១ និងលេខ ១៤ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥0 មាត្រា ៦(១)។ កតិកាសញ្ញាទ្វីបអាមេរិកាំងស្តីពីសិទ្ធិមនុស្ស "Pact of San Jose" ប្រទេសកូស្តារិកា លេខ ETS 5 ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩ មាត្រា ៨(២)(១)។ ធម្មនុញ្ញទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន CAB/LEG/67/3 វិសោធនកម្មលើកទី ៥ លេខ 21 I.L.M. (១៩៨២) មាត្រា ៧(១)(ឃ)។ លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ លេខ 2187 UNTS 90 ("លក្ខន្តិកៈទីក្រុងរ៉ូម") មាត្រា ៦៧(១)(គ)។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ ដែលបានធ្វើបច្ចុប្បន្នភាព ("លក្ខន្តិកៈតុលាការ ICTY") មាត្រា ២0(១) និង ២១(៤)(គ)។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលបានធ្វើបច្ចុប្បន្នភាព ("លក្ខន្តិកៈតុលាការ ICTR") មាត្រា ១៩(១) និង ២0(៤)(គ)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២00២ មាត្រា ១៧(៤)(គ)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសឡេបាណន់ ចុះថ្ងៃទី១0 ខែមិថុនា ឆ្នាំ២00៧ មាត្រា ១៦(៤)(គ)។

[111] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង 00៤/២ កថាខណ្ឌ ៦៩។

[112] *សូមមើលខាងលើ* ជើងទំព័រ ៣៨។

បញ្ហាផ្សេងៗថា នៅពេលដែលតុលាការបានសម្រេចចុងក្រោយលើបញ្ហាមួយ ការសម្រេចរបស់តុលាការនោះមិនគួរលើកមកជាបញ្ហាឡើយ[113]។ នៅក្នុងសេចក្ដីសម្រេចមួយទៀត តុលាការនេះសម្រេចថា ការកាត់សេចក្ដីមិនមានសង្គតិភាពលើការទាមទាររបស់បុគ្គលក្នុងស្ថានភាពប្រហាក់ប្រហែលគ្នានាំដល់ភាពមិនប្រកដប្រជាដែលកាត់បន្ថយ សេចក្ដីទុកចិត្តរបស់ សាធារណជនទៅលើប្រព័ន្ធតុលាការនិងដកសិទ្ធិរបស់បុគ្គលក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌[114]។ ប្រសិនបើ ស.ច.ស បច្ចុប្បន្ននេះយកសំអាងហេតុផ្សេងមកអនុវត្តចំពោះ យឹម ទិត្យ និង សន្និដ្ឋានថារឿងក្ដីនេះមិនគួរបិទបញ្ចប់ ដោយសារមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនោះ មានន័យថា យឹម ទិត្យ អាចត្រូវបានប្រព្រឹត្តដោយផ្អែកលើវិធានផ្សេងពី អោ អាន ដែលនាំដល់ភាពមិនប្រាកដប្រជាចំពោះនីតិវិធីដែលគ្រប់គ្រងលទ្ធផលនៃរឿងក្ដីនេះ។

43. ការបដិសេធក្នុងការសម្រេចសំណុំរឿង០០៤ ជាបន្ទាន់ អាចមានន័យស្មើនឹងទទួលអនុវត្តមិនស្មើគ្នាចំពោះ រឿងក្ដី០០៤/២ ដែលត្រូវបានដាក់ក្នុងបណ្ណាសារដោយ ស.ច.ស ភ្លាមៗនៅពេលពួកគាត់បានដឹងដោយមិនអាចចៀសបានថា យន្តការផ្នែកនីតិវិធីទាំងអស់ផ្សេងទៀតត្រូវបានប្រើប្រាស់អស់ហើយ។ ការបដិសេធមិនអនុវត្តនូវការប្រព្រឹត្តស្មើគ្នាចំពោះ យឹម ទិត្យ ជាមួយនឹង អោ អាន អាចបង្កើតការរំលោភដ៏ច្បាស់ក្រឡែតលើមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[115]។

44. គោលការណ៍សច្ចភាពផ្លូវច្បាប់តម្រូវថា តុលាការធ្វើសេចក្ដីសម្រេចច្បាស់លាស់និងមានសង្គតិភាពដើម្បីឲ្យមានការអនុវត្តវិធានច្បាប់ដូចគ្នាចំពោះមនុស្សក្នុងក្រុមស្មើរតែដូចគ្នាក្នុងវិធីដូចគ្នា ដែលតម្រូវក្នុងចំណោមបញ្ហាផ្សេងៗថានៅពេលតុលាការបានសម្រេចចុងក្រោយលើបញ្ហាមួយ ការសម្រេច

---

[113] តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប រឿងក្ដីរវាង *Brumărescu ទល់នឹង ប្រទេសរូម៉ានី* សំណុំរឿងលេខ លេខ ២៨៣៤២/៩៥ សាលក្រម ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦១។

[114] តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប រឿងក្ដីរវាង *Ştefănică និងអ្នកផ្សេងទៀត ទល់នឹង ប្រទេសរូម៉ានី* សំណុំរឿងលេខ ៣៨១៥៥/០២ សាលក្រម ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៣៧ និង ៣៨។

[115] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១៖ “ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់”។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៖ “បណ្ដឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ សាភា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ *ស្ថានភាពឯទៀតឡើយ* (បញ្ជាក់បន្ថែម)។

របស់តុលាការនោះមិនគួរលើកមកជាបញ្ហាឡើយ[116]។ ការកាត់សេចក្ដីមិនមានសង្គតិភាពលើសំណុំរឿង០០៤ នៅក្នុងរបៀបផ្សេងគ្នាពីសំណុំរឿង០០៤/០២ (សំណុំរឿងទាំងពីរពាក់ព័ន្ធនឹងការសម្រេចតាមស្ថានភាពនីតិវិធីដូចគ្នា) រំលោភសិទ្ធិ យឹម ទិត្យ ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និងថែមទាំងកាត់បន្ថយសេចក្ដីទុកចិត្តរបស់សាធារណជនជាតិនិងអន្តរជាតិចំពោះប្រព័ន្ធតុលាការ អ.វ.ត.ក[117]។

45. ដូចនេះ ស.ច.ស ត្រូវបំពេញកិច្ចដើម្បីជៀសវាងសេណារីយ៉ោនៃភាពមិនប្រាកដប្រជាក្នុងសំណុំរឿង ០០៤ ចំពោះនីតិវិធីដែលគ្រប់គ្រងលទ្ធផលនៃរឿងក្ដីនៅក្នុងដំណាក់កាលមុនជំនុំជម្រះនៃកិច្ចនីតិវិធី អ.វ.ត.ក។ សំណុំរឿង០០៤ បានទទួលរងនូវព្យសនកម្មនីតិវិធីដែលមិនអាចកែតម្រូវបានដូចជាឥឡូវនេះមិនអាចជំនុំជម្រះក្ដីដោយយុត្តិធម៌បាន ហើយការបន្តកិច្ចនីតិវិធីនឹងបង្កជាការរំលោភនីតិវិធី។ នៅក្នុងកាលៈទេសៈបែបនេះ វាអាចជាការប្រមាថទៅលើសញ្ញាណយុត្តិធម៌ និងភាពសមរម្យក្នុងការកាត់សេចក្ដីលើ យឹម ទិត្យ[118]និង "គួរឲ្យស្អប់ខ្ពើម" ឬ "មិនស៊ីសង្វាក់គ្នា" ជាមួយនឹងកិច្ចការរដ្ឋបាលតុលាការក្នុងការអនុញ្ញាតឲ្យបន្តកិច្ចដំណើរការនីតិវិធី[119]។ គោលការណ៍ដែលថាតុលាការមានកាតព្វកិច្ចមិនបន្តកិច្ចដំណើរការនីតិវិធីដែលខូចគុណភាព មិនអាចកែតម្រូវបានមុនពេលការសម្រេចចុង

---

[116] *សូមមើលខាងលើ* ជើងទំព័រ ៣៨។

[117] តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប រឿងក្ដីរវាង *Ştefănică និងអ្នកផ្សេងទៀត ទល់នឹង ប្រទេសរូម៉ានី* សំណុំរឿងលេខ ៣៨១៥៥/០២ សាលក្រម ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៣៧។ (សេចក្ដីបញ្ជាក់ខាងក្នុងត្រូវបានលុបចោល)។ ការវិនិច្ឆ័យសេចក្ដីមិនស៊ីសង្វាក់គ្នានៃបណ្ដឹងដែលបានប្ដឹងដោយបុគ្គលទាំងឡាយ នៅក្នុងស្ថានភាពស្រដៀងគ្នា បណ្ដាលឲ្យមានស្ថានភាពមិនច្បាស់លាស់ ដែលនាំឲ្យបាត់បង់ជំនឿទុកចិត្តពីសំណាក់សាធារណជនមកលើសាលាជម្រះក្ដី និងដកហូតពីបុគ្គលទាំងឡាយនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ *សូមមើល ដូចខាងលើ* កថាខណ្ឌ ៣៨។

[118] *សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២* ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D355កថាខណ្ឌ ៣៩។ ចក្រភពអង់គ្លេស *R ទល់នឹង តុលាការ Horseferry Road Magistrates [១៩៩៤] 1 A.C. 42 H.L.(E) 74G*។ *សូមមើលផងដែរ:* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR រឿងក្ដីរវាង *Barayagwiza ទល់នឹង រដ្ឋអាជ្ញា* (សំណុំរឿងលេខ ICTR-97-19-AR72) "សេចក្ដីសម្រេច" ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៧៤-៧៥, ៧៧។

[119] អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Lubanga* "សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ជំទាស់នឹងសេចក្ដីសម្រេចលើការជំទាស់តវ៉ារបស់ក្រុមមេធាវីការពារក្ដីទៅនឹងយុត្តាធិការរបស់តុលាការនេះ ដោយអនុលោមតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ សំណុំរឿងលេខ ICC-01/04-01/06-772 កថាខណ្ឌ ២០, ៣០ និង ៣៧។

ក្រោយលើរឿងក្តីមួយនោះ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយក្នុងច្បាប់កម្ពុជា ដោយតុលាការអន្តរជាតិ និង អ.វ.ត.ក ក្នុងនោះរួមមាន ស.ច.ស ទាំងនេះផងដែរ[120]។

## ផ្នែកទី ៣÷ សេចក្តីសន្និដ្ឋាន

46. ក្រោយពីការស៊ើបអង្កេតដែលអូសបន្លាយរយៈពេលជាង១៥ឆ្នាំមក និងបន្ទាប់ពីយន្តការផ្លូវច្បាប់ទាំងអស់ត្រូវបានប្រើប្រាស់អស់ហើយនោះ ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពក្នុងសំណុំរឿង004 ឡើយ។

---

[120] *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង 003 សំណុំរឿង 004 និងសំណុំរឿង 004/2 និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D355/9 កថាខណ្ឌ ១៦។ សំណុំរឿង 002 *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង 002* ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ E284/4/8កថាខណ្ឌ *៧៥។ សូមមើល ឧទាហរណ៍:* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Lubanga* "សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ជំទាស់នឹងសេចក្តីសម្រេចលើការតវ៉ារបស់ក្រុមមេធាវីការពារក្តីទៅនឹងយុត្តាធិការរបស់តុលាការនេះ ដោយអនុលោមតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ សំណុំរឿងលេខ ICC-01/04-01/06-772 កថាខណ្ឌ ២៦-៣៩។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Tadić* (សំណុំរឿងលេខ IT-94-1-A) "សាលដីកាសម្រេចលើការចោទប្រកាន់អំពីការមាក់ងាយតុលាការប្រឆាំងនឹងមេធាវីការពារក្តីមុនឈ្មោះ Milan Vujin ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ កថាខណ្ឌ ១៣។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Stanišić និង" Župljanin* (សំណុំរឿងលេខ IT-08-91-A) "សាលដីកាសម្រេចលើសំណើរបស់ Mićo Stanišić ស្នើសុំការប្រកាសអំពីការជំនុំជម្រះខុស និងសំណើរបស់ Stojan Župljanin សុំឱ្យធ្វើមោឃភាពសាលក្រម ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៣៥។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Karadžić* (សំណុំរឿងលេខ IT-95-5/18-AR-73-4) "សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Karadžić ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការចោទប្រកាន់អំពីកិច្ចព្រមព្រៀង Holbrooke" ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ៤៥។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Karadžić* (សំណុំរឿងលេខ IT-02-62-AR54 *ស្ទួន*) "សាលដីកាសម្រេចលើការជំទាស់តវ៉ាពីសំណាក់ប្រទេសក្រូអាស៊ីទៅនឹងសេចក្តីសេចក្តីសម្រេច និងសេចក្តីបង្គាប់របស់ចៅក្រមដែលបញ្ជាក់អះអះអាង" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ១៥។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR រឿងក្តីរវាង *Barayagwiza ទល់នឹង រដ្ឋអាជ្ញា* (សំណុំរឿងលេខ ICTR-97-19-AR72) "សេចក្តីសម្រេច" ចុះថងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៧៣ ដល់ ៧៧។ *សូមមើលផងដែរ* សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូនរឿងសំណុំរឿង 003 កថាខណ្ឌ ៣៧។

47. ជាការច្បាស់ណាស់ថា ស.ច.ស មានយុត្តាធិការផ្តាច់មុខ និងសិទ្ធិអំណាចក្នុងការបិទបញ្ចប់សំណុំរឿង០០៤ ហើយ ស.ច.ស ត្រូវតែបិទបញ្ចប់សំណុំរឿង០០៤ ជាបន្ទាន់ ដើម្បីបញ្ចៀសកុំឱ្យមានព្យសនកម្មមិនអាចកែតម្រូវបានបន្ថែមទៀតចំពោះសិទ្ធិរបស់ យឹម ទិត្យ ក្នុងការទទួលបានការសម្រេចឱ្យបានឆាប់រហ័សលើកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ សិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើភាព និង សច្ចភាពផ្លូវច្បាប់។

48. ក្នុងសំណុំរឿង០០៤/២ ស.ច.ស បានបោះត្រា និងដាក់សំណុំរឿងក្នុងបណ្ណសារ ដោយផ្អែកលើការបិទបញ្ចប់របស់ អ.ជ.ត.ក និងតាមរយៈការអនុវត្តគោលការណ៍ដូចគ្នានៃវិធាន៦៩(២)(ខ)[121]។ ឥឡូវនេះ ស.ច.ស ត្រូវតែសម្រេចនូវភាពស្ថាពរដូចគ្នាក្នុងសំណុំរឿង០០៤ ដោយមិនពន្យារពេលឡើយ។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើដោយគោរពដល់សហចៅក្រមស៊ើបអង្កេត ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន និងក្នុងប្រយោជន៍យុត្តិធម៌ មេត្តា៖

(1) អនុញ្ញាតលើសំណើសុំបិទបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង០០៤ ទៅក្នុងបណ្ណសារដែលមានអានុភាពអនុវត្តជាបន្ទាន់។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

**សូ មូស្សេនី** **Suzana TOMANOVIĆ**

សហមេធាវីការពារក្តីលោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២១

[121] ដីកាបង្គាប់ឱ្យដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ឯកសារ D363/3 កថាខណ្ឌ ៩។